# សម្ភាសន៍ជាមួយឈ្មោះ អៀយ ពៀ ភេទប្រុស អាយុ៩៨ឆ្នាំ

**មុខរបរសម័យខ្មែរក្រហមៈ កងចល័តនៅព្រៃមាន់**

**ទីកន្លែងកំណើតៈ ភូមិឈូក ឃុំម្កាក់ ស្រុកសេរីសោភ័ណ្ឌ ខេត្តបាត់ដំបង**

**សព្វថ្ងៃរស់ៈ គង់នៅក្នុងវត្តក្បាលទន្សោង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**ថ្ងៃទី ២៤ ខែ៥ ឆ្នាំ២០១៥**

**រយៈពេលៈ ០១:១២:៥១**

**ទំព័រសរុបៈ ៤៦ ទំព័រ**

ឡុង ដានីៈ ខ្ញុំករុណា! ដំបូងចង់ស្គាល់ព្រះនាមព្រះអង្គ? ព្រះអង្គឈ្មោះ?

អៀយ ពៀៈ ឈ្មោះ អៀយ ពៀ ។

ឡុង ដានីៈ អើយ ពណ៌! 'អ' ដាក់ ស្រះ 'ើ' ។

អៀយ ពៀៈ ហ្នឹងហើយ! ស្រះ 'ៀ' ក៏បាន ។

ឡុង ដានីៈ ស្រះ 'ៀ' ហ្នឹង 'យ' ។ អៀយ ពណ៌ ។

អៀយ ពៀៈ 'ព' ស្រះ ៀ ។ ស្រះ ៀ ទៀត

ឡុង ដានីៈ 'ព' ដាក់ស្រះ 'ៀ' ពៀ ។ អញ្ចឹង! អៀយ ពៀ ។ សព្វថ្ងៃនេះ ព្រះអង្គព្រះជន្ម ប៉ុន្មានហើយ?

អៀយ ពៀៈ គិតមើល ឆ្នាំរកា ។ វា .......... ។

ឡុង ដានីៈ ឆ្នាំរកា! ឆ្នាំរកាខ្ទង់៩០ជាង ។

អៀយ ពៀៈ ខ្ទង់៩០ ។ ៩៨ដឹង ។

ឡុង ដានីៈ ៩៨!

អៀយ ពៀៈ ប្រហែលជា៩៨ ។

ឡុង ដានីៈ ៩៨! ព្រះអង្គ ស្រុកកំណើតកើតជាអីនៅណាដែរ?

អៀយ ពៀៈ នៅឈូក បែកបានម្កាក់ ។

ឡុង ដានីៈ នៅភូមិអ្វីដែរហ្នឹង?

អៀយ ពៀៈ នៅភូមិឈូក ។

ឡុង ដានីៈ ភូមិឈូក ។

អៀយ ពៀៈ ភូមិឈូក ឃុំម្កាក់ ។

ឡុង ដានីៈ ឃុំម្កាក់!

អឿយ ពឿៈ ពីដើមមក ស្រុកស៊ីសូផុន ។ ស្រុកសេរីសោភ័ណ្ឌ ពីដើមមក ។

ឡុង ដានីៈ ស្រុកសេរីសោភ័ណ្ឌ ។

អឿយ ពឿៈ ខេត្តបាត់ដំបងដែរ ។

ឡុង ដានីៈ ហើយ ញ៉ោមព្រះអង្គ គាត់ ញ៉ោមប្រុសឈ្មោះអ្វីដែរ?

អឿយ ពឿៈ ញ៉ោម ឈ្មោះប៉ូច ។

ឡុង ដានីៈ ញ៉ោម ឈ្មោះប៉ូច!

អឿយ ពឿៈ ញ៉ោម ឈ្មោះប៉ូច!

ឡុង ដានីៈ ហើយ ញ៉ោមស្រី?

អឿយ ពឿៈ ឈ្មោះ រីម សាលីន ។

ឡុង ដានីៈ រីម សាលីន! ញ៉ោមព្រះអង្គគាត់នៅរស់ នៅដល់....?

អឿយ ពឿៈ អត់ទេ! ញ៉ោម សម័យនោះ គាត់រត់ទៅថៃ ។

ឡុង ដានីៈ រត់ទៅថៃ!

អឿយ ពឿៈ គាត់រត់ ដល់រត់ទៅថៃ ភូមិអាត្មានេះប្រវត្តិអាក្រក់ហើយណា ។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ ប្រវត្តិអាក្រក់ហើយ គឺ គេថា គេចោទថា កូនអាខ្មាំង ។ គេចោទថា អានាយទុន ។ គេចោទថា អាសក្តិភូមិអីហើយ ។

ឡុង ដានីៈ ហើយ ញ៉ោមព្រះអង្គ រត់ទៅឆ្នាំណាទៅ?

អឿយ ពឿៈ រត់ទៅចុងឆ្នាំ៧៥ ចូល៧៦ ។

ឡុង ដានីៈ អើម! រត់ពីខាង ......

អឿយ ពឿៈ រត់ពីផ្ទះនៅភូមិនេះ ។

ឡុង ដានីៈ ពីឈូក ពីម្កាក់ហ្នឹងទៅបណ្តោយ ។

អឿយ ពឿៈ ទៅបណ្តោយ!

ឡុង ដានីៈ ហើយ ព្រះអង្គ មានបងប្អូនប៉ុន្មាននាក់ដែរ?

អឿយ ពឿៈ ៥នាក់ ។

ឡុង ដានីៈ បងប្អូន៥នាក់ ។ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

អឿយ ពឿៈ ស្រី៣ ប្រុស២ ។

ឡុង ដានីៈ ស្រី៣ ប្រុស២ ។ ព្រះអង្គ ទីប៉ុន្មាននៅក្នុងគ្រួសារ?

អឿយ ពឿៈ ទី១ ។

ឡុង ដានី: បងគេបង្អស់ ។

អឿយ ញឿ: បងគេបង្អស់!

ឡុង ដានី: ហើយពេលដែលញ៉ោមប្រុសញ៉ោមស្រីរបស់ព្រះអង្គរត់ទៅហ្នឹង កូនចៅរត់ទៅជាមួយដែរអត់ទេ?

អឿយ ញឿ: អត់ទេ! អត់មានទៅទេ ។

ឡុង ដានី: ទៅតែពីរនាក់គាត់?

អឿយ ញឿ: ទៅតែគាត់ ។

ឡុង ដានី: គាត់ធ្វើអ្វី បានជារត់ទៅ ញ៉ោមព្រះអង្គ?

អឿយ ញឿ: ពីដើមមក គាត់ធ្វើទាហាន ។

ឡុង ដានី: គាត់ធ្វើទាហាន?

អឿយ ញឿ: គាត់ធ្វើទាហាន ។ ដល់ក្រោយមក ដល់សម័យខ្មែរក្រហមគេតស៊ូ គេដឹងថាគាត់មនុស្សចេះ ។ គេដឹងថាគាត់មនុស្សចេះ ហើយគេដឹងថាគាត់មនុស្សចេះ គេយកគាត់ឲ្យធ្វើបណ្ដាញខ្មែរក្រហម ។ ឲ្យបណ្ដាយខ្មែរក្រហម គាត់ក៏ធ្វើ ។ គាត់ធ្វើដឹកនាំបងប្អូនអ្នកស្រុកចូលព្រៃ ។ ដល់ពេលចុងក្រោយមក គេឲ្យគាត់ធ្វើមេឃុំ សម័យ៣ឆ្នាំណា៎

ឡុង ដានី: ករុណា!

អឿយ ញឿ: ឲ្យគាត់ធ្វើមេឃុំ ។ ដល់ពេលធ្វើមេឃុំ គាត់និយាយខុស ។ គាត់និយាយខុសថាអញ្ចេះ គាត់និយាយខុសថា "ស៊ូៗទៅ បងប្អូនអើយ! ធ្វើម៉េច បើយើងវាត្រូវអញ្ចេះឯង ៗ"

ឡុង ដានី: តស៊ូហ្នឹង?

អឿយ ញឿ: ហ្នឹងហើយ ។ តស៊ូ ស៊ូទៅ ។ ស៊ីអត់ស៊ីឃ្លានទៅ សូម្បីតែខ្ញុំក៏ដូចតែគ្នា ។ គាត់ថាអញ្ចេះ "ខ្ញុំបើគេដកឲ្យឃ្វាលគោ ខ្ញុំទៅឃ្វាលគោ ឆាប់ឃើញព្រៃដង ។" ថាអញ្ចេះ ។ នេះខុសទីនេះឯង ។

ឡុង ដានី: ខុសកន្លែងហ្នឹង?

អឿយ ញឿ: គេដកបណ្ដោយ ។

ឡុង ដានី: គេដកបណ្ដោយ!

អឿយ ញឿ: គេដកឲ្យឈប់ធ្វើមេឃុំ គេតាមដាន ។

ឡុង ដានី: ករុណា!

អឿយ ញឿ: ដល់ណាគិត គិតទៅ គាត់ដឹងខ្លួនថា គាត់មុខតែងាប់ថ្ងៃណាហើយ ។ ប៉ុន្តែដល់នេះគាត់រត់ គាត់រត់ក៏អាត្មាមិនបានដឹង អាត្មាទៅនៅកងភ្នូរ ។ អាត្មាទៅនៅកងភ្នូរ

អត់ដឹងថាឪពុកខ្លួនឯងរត់ទេ។ មេឃុំគេហៅមកសួរ។ មេឃុំគេហៅ មកសួរថា អូនឯងមានដឹងថាឪពុកអូនឯងរត់ទេ? ថាទេ ខ្ញុំម៉េចដឹងបង បើខ្ញុំនៅឯណា គោកឆ្កែ ស្រែងអីណោ៎ះ។ ហើយខ្ញុំតែភ្ជួរ សួរទៅចាស់ៗកងភ្ជួរ។ នេះថា អើ បើប្អូនឯងមិនដឹង ទៅវិញក៏ទៅទៅ។ ហើយគេសួរអាត្មាទៀតថា អូនឯងស្គាល់ដាវនេះទេ? អាត្មាថាស្គាល់ ប៉ុន្តែដាវនោះអត់មែនដាវញ៉ោមអាត្មាទេ។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ ដាវអ្នកផ្សេង ប៉ុន្តែ ដូចជា អាត្មាដូចជាសំណាងវាដែលត្រូវរស់ណា៎។ ថាស្គាល់មែន ដាវនេះ ដាវពុកខ្ញុំ។ បេះគាត់ មេឃុំគេថា អើ ពុកមិត្តឯងងាប់ហើយ។ ងាប់ទៅ គាត់ក្បត់ជាតិ។ អាត្មាថាអញ្ចោ៎ះថា "ងាប់ៗទៅ គាត់ក្បត់ជាតិ" ប៉ុន្តែអាត្មានឹកស្រមៃថា ញ៉ោមអាត្មាអត់ងាប់ទេ។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ អត់ចាប់បានទេ ញ៉ោមអាត្មា ប៉ុន្តែរត់ គាត់រត់ព្រឹកដែរណា៎។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ គាត់រត់ព្រឹក។ រត់ទៅ គេដេញចាប់គាត់ ប៉ុន្តែគាត់ ដូចថាគាត់បានបួសបានរៀនណា៎។ គាត់បានបួសបានរៀនទៅ គាត់មើលទៅឃើញបាត់ៗហ្នឹង គាត់ហ្នឹង។ ដែលគាត់រស់យូរណា៎ ដែលមើលទៅឃើញបាត់ៗ។

ឡុង ដានីៈ បានន័យថា ដូចថា គេមើលទៅឃើញទៅ បាត់ៗ?

អឿយ ពឿៈ ហ្នឹងហើយ! បាត់ទៅវិញ។ គាត់ធ្វើឲ្យឃើញ ឃើញ។ គាត់ធ្វើឲ្យបាត់ បាត់ៗ។ បានជាគាត់រត់រួចនោះ។ គាត់រត់នោះ។

ឡុង ដានីៈ គាត់រត់ទៅឆ្នាំណាទៅ?

អឿយ ពឿៈ គាត់រត់ទៅឆ្នាំ ចុងឆ្នាំ៧៥ ដើមឆ្នាំ៧៦។

ឡុង ដានីៈ ករុណា!

សុខ វណ្ណៈ អញ្ចឹង! គាត់រត់រួច?

អឿយ ពឿៈ រត់រួច។

ឡុង ដានីៈ ទាំងញ៉ោមស្រី ទាំងញ៉ោមប្រុស?

អឿយ ពឿៈ ទេ! ញ៉ោមស្រីទៅមិនរួចទេ។ ញ៉ោមស្រីមិនបានទៅទេ ទៅតែញ៉ោមប្រុស។

ឡុង ដានីៈ ទៅតែញ៉ោមប្រុស?

អឿយ ពឿៈ ប៉ុន្តែ គាត់យកប្រពន្ធចុងគាត់ទៅបាន។ ប្រពន្ធចុង គាត់យកប្រពន្ធចុងមួយទៅបាន។ គាត់ទៅពីរនាក់ប្រពន្ធចុង។

ឡុង ដានីៈ ប្រពន្ធចុងនៅណា?

អឿយ ពឿៈ នៅសង្កា

ឡុង ដានីៈ នៅសង្កា

អឿយ ពឿៈ នៅសង្កា

ឡុង ដានីៈ នៅសង្កា។ ហើយរត់ទៅ គាត់រត់ទៅដល់ថៃ?

អឿយ ពឿៈ រត់ទៅដល់ថៃទៅ។ គាត់ទើបតែខូចទេ។

ឡុង ដានីៈ អើម ទើបតែខូច!

អឿយ ពឿៈ គាត់ធ្វើវិហារម្កាក់នេះ។ គាត់ចុះមកធ្វើវិហារម្កាក់រួច។ វិហារម្កាក់នោះ គាត់ធ្វើទេ។

ឡុង ដានីៈ វិហារម្កាក់?

អឿយ ពឿៈ នោះវិហារម្កាក់។

ឡុង ដានីៈ ហើយដល់ពេលញៀមព្រះអង្គរត់ទៅអញ្ចឹង កូនចៅប្រពន្ធកូនអីអត់អីទេ? គេអត់ធ្វើអីទេ?

អឿយ ពឿៈ ទេ! គេប្រុងដែរ។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ ដូចថា បានអាត្មាជឿទៅលើបុណ្យ ជឿទៅលើបាបណ៎ ព្រោះថា ដឹកពអាកាំម៉ាស មកដឹកឃុំម្កាក់ ពអាកាំម៉ាស អ្នកដែលគ្រួសាររត់ទៅថៃ។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ ហើយនៅសល់មួយគ្រួសារអាត្មានេះ។ គេអត់ដឹកទេ ប៉ុន្តែមេភូមិប្រាប់ដែរថា នៅហ្នឹងឈូកមួយ។ ប៉ុន្តែចៅហ្វាយស្រុកគេកាលហ្នឹង នៅតែពាយ័ព្យទេ មិនទាន់និរតីទេ កាលហ្នឹងណ៎។

ឡុង ដានីៈ កាលហ្នឹង ចៅហ្វាយស្រុកគេឈ្មោះអ្វីដែរ?

អឿយ ពឿៈ ឈ្មោះ ស៊ិន។

ឡុង ដានីៈ ឈ្មោះ ស៊ិន ចៅហ្វាយស្រុកសេរីសោភ័ណ្ឌ?

អឿយ ពឿៈ ហ្នឹងហើយ។ ចៅហ្វាយស្រុសេរីសោភ័ណ្ឌមកនៅឃុំម្កាក់នេះ ឈ្មោះ ស៊ិន។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ ឈ្មោះ ស៊ិន។ គ្នាគេពនាក់ៈ ១-សុត ១-រ៉ុត។

ឡុង ដានី៖ ឈ្មោះ សុត រ៉ត ហើយហ្នឹង?

អឿយ ពឿ៖ រ៉ុត សុត ស៊ិនៗ ស៊ិនហ្នឹងមេគេៗ

ឡុង ដានី៖ អ៊ូ! ស៊ិនមេគេៗ ហើយបាន សុត...?

អឿយ ពឿ៖ សុត អនុៗ

ឡុង ដានី៖ សុត អនុ!

អឿយ ពឿ៖ សុត អនុៗ រ៉ុត សមាជិកៗ

ឡុង ដានី៖ ករុណា! ហើយកាលហ្នឹង ក្រុមគ្រួសារព្រះអង្គនៅភូមិឈូកហ្នឹងដែរ?

អឿយ ពឿ៖ នៅភូមិឈូកៗ

ឡុង ដានី៖ ហើយព្រះអង្គ គេឲ្យទៅធ្វើកងក្ដួរអីនៅណាដែរកាលហ្នឹង?

អឿយ ពឿ៖ កាលហ្នឹង ដល់ពេលញ៉ោមរត់ផុត បានបក្សពួកក្រុមយុវជនគេខ្វាចអាគ្នាងរប់ដែលគ្នាឯង ដែលស្រុកត្រូវគ្នាមកគេនឹកអាណិតគេក៏ឲ្យកងយុវជនទៅតាមឲ្យមកនៅជាមួយយុវជននៅភូមិនោះហើយកាលនោះៗ ដល់ក្រោយមកទៀត បានគេប្រមូលយុវជនមកទុកម្ដាក់ៗ ដល់ក្រោយមកទៀត បានគេប្រមូលទៅត្រពាំងថ្មៗ

ឡុង ដានី៖ ដល់ឆ្នាំណាបានគេប្រមូលមកត្រពាំងថ្ម?

អឿយ ពឿ៖ ប្រហែលជាឆ្នាំចិតសិបៗ..... ៧៦នេះ ដើមឆ្នាំ៧៦នេះ ព្រោះប្រមូលទៅកាលនោះប្រមូលទៅខែប្រ៊ូតៗ

ឡុង ដានី៖ ដើមឆ្នាំ៧៦?

អឿយ ពឿ៖ ហ្នឹងហើយៗ ដើមឆ្នាំ៧៦ៗ

ឡុង ដានី៖ កាលហ្នឹង គេប្រមូលទៅត្រពាំងថ្មទៅធ្វើអ៊ីទៅ?

អឿយ ពឿ៖ លើកអាងៗ

ឡុង ដានី៖ ទៅលើកអាង!

អឿយ ពឿ៖ លើកអាងៗ ១ថ្ងៃ ៣ម៉ែត្រគីបណាំៗ

ឡុង ដានី៖ ១ថ្ងៃ ៣ម៉ែត្រគីប!

អឿយ ពឿ៖ ១ថ្ងៃ ៣ម៉ែត្រគីបៗ ហើយដីសុទ្ធតែកាប់ សុទ្ធតែព្រាយៗណែ៎ៗ

ឡុង ដានី៖ រាំង?

អឿយ ពឿ៖ នេះកងពិសេសៗ កងពិសេសឃុំម្ដាក់នេះ នេះកងពិសេសណាៗ ក្បាលស្ពានទី១រលំធំៗ លើករួច២កន្លែងៗ លើកទី១លើករលំធំ គេហៅថារលំធំៗ លើករួច

មុនគេ បានគេយកទៅដាក់ ដាក់នៅក្បាលស្ពានទី១ ។ ក្បាលស្ពានមកពីត្រពាំងថ្ម ។ កងអាត្មានេះឯង ។

ឡុង ដានី: កាលហ្នឹង មនុស្សលើកនៅត្រពាំងថ្មច្រើនទេ?

អឿយ ពឿ: អ៊ូ! គេចគ្នាមិនរួចទេ ។

ឡុង ដានី: ច្រើនណាស់ ។

អឿយ ពឿ: ច្រើនណាស់ ។ គេចគ្នាដាច់ ទឹកក៏ដាច់ ។

ឡុង ដានី: ហើយហូបចុក អាហារហូបចុក ទឹកអី កន្លែងបរិភោគអី គ្រប់គ្រាន់ដែរ?

អឿយ ពឿ: អត់ទេ ។ ទឹកយ៉ាប់ ទឹក ។

ឡុង ដានី: យ៉ាប់ទឹក!

អឿយ ពឿ: យ៉ាប់ទឹក ។ កាលហ្នឹង បាយ គេបើកឲ្យហូប ។ គេឲ្យហូបបាយណា៎ ។ ដូចជា ប្រហុក បើកប្រហុកឲ្យ ។

ឡុង ដានី: ហើយកាលហ្នឹង អ្នកគម្រោងអាងត្រពាំងថ្មហ្នឹងមកពីណាទៅ? អ្នកឲ្យធ្វើ ឲ្យលើក ។

អឿយ ពឿ: មិនដឹងទេ ។ អាត្មាក៏មិនដឹង ។ មិនដែលហ៊ានទៅសួរនាំគេអីនោះ ។ ប៉ុន្តែអ្នកដែលចាត់តាំងទៅ គឺតំបន់នេះឯង ។

ឡុង ដានី: តំបន់?

អឿយ ពឿ: តំបន់៥នេះឯង ។ ទៅ ទៅនៅតាមស្រុក ។ ស្រុកថ្មពួកនៅទីនេះ ស្រុកស៊ីសុផុនទីនោះ ស្រុកភ្នំស្រុកនោះទីនោះ ។ អញ្ចេះណា៎! បាន បានមាននៅលាយឡំគ្នាអីទេ បែកគ្នាតាមស្រុកៗ តាមមុខព្រួញ ។

ឡុង ដានី: អ៊ូ!

អឿយ ពឿ: អាត្មាមិនហ៊ានសួរទេៗ ។

ឡុង ដានី: ប៉ុន្តែ អ្នកគ្រប់គ្រងធំគេអត់ដឹងទេ អ្នកគ្រប់គ្រង ការគ្រប់គ្រងត្រពាំងថ្មទាំងមូលហ្នឹង?

អឿយ ពឿ: ដឹង! ដឹងតែគណៈតំបន់ ។ ដឹងតែតំបន់ៗ ។

ឡុង ដានី: ពីណាគេគណៈតំបន់កាលហ្នឹង?

អឿយ ពឿ: ឈ្មោះ ហឹង ។

ឡុង ដានី: ឈ្មោះ តា ហឹង!

អឿយ ពឿ: ហ្នឹងហើយ ឈ្មោះ ហឹង ។

ឡុង ដានី: តា ហឹង គណៈតំបន់ ។ ចុះបន្តបន្ទាប់ពី តា ហឹង?

អឿយ ពឿ: មិនមានស្គាល់ទេ ។ មានស្គាល់តែ កូនប្រសា ដាល ។ ឈ្មោះ ដាល ។

ឡុង ដានី:	ដាលហ្នឹងកូនរបស់ពីណាគេ?
អឿយ ពឿ:	កូនប្រសា តា ហឹង។ កូនតា ញឹម។ កូនគណះភូមិភាគ។
ឡុង ដានី:	កូនគណះភូមិភាគ។
អឿយ ពឿ:	ហ្នឹងហើយ កូនគណះភូមិភាគ។ ប៉ុន្តែស្គាល់នោះ ក៏មិនស្គាល់បានច្បាស់ទេណា៎។
ឡុង ដានី:	ករុណា!
អឿយ ពឿ:	មិនស្គាល់បានច្បាស់ទេ។ គ្រាន់តែយូរៗទៅ គេមកម្តងទៅ ឯងក៏អើតមើលគេទៅ។
ឡុង ដានី:	អើម! ហឹង ហើយ ដាល។ ក្រោយមក ឈ្មោះ ដាល?
អឿយ ពឿ:	ឈ្មោះ ដាល។
ឡុង ដានី:	ហើយ ហឹង ហើយ ដាលហ្នឹង គេយកទៅណាទៅ?
អឿយ ពឿ:	ដល់និរតីចូលមក គេប្រមូលទៅអស់។
ឡុង ដានី:	អ៊ូ! គេប្រមូលទៅអស់។
អឿយ ពឿ:	ងាប់មួយសារដែរ។
ឡុង ដានី:	អ៊ូ!
អឿយ ពឿ:	ងាប់នៅកកោះ មោងយើងនេះ។
ឡុង ដានី:	គេយកទៅកកោះ មោង?
អឿយ ពឿ:	គេយកទៅកកោះមោងសម័យនោះឯង។ ប៉ុន្តែពួកអ្នកធំៗ មិនដឹងគេយកទៅទុកឯណា មិនដឹងទេ។ ប៉ុន្តែរឿងអ្នកតូចៗ កូនចៅអី កកោះហើយមោងហើយ។
ឡុង ដានី:	ហើយចុះ ដាល ហើយ ហឹងអី ទៅដល់ណាទៅ?
អឿយ ពឿ:	មិនដឹងថា ទៅណាទេ។ បាត់រូបអីកាលនោះឯង។
ឡុង ដានី:	អើម!
អឿយ ពឿ:	បាត់រូបអស់។
ឡុង ដានី:	ហើយលោកតាអញ្ចឹង កាលពីសម័យ គេឲ្យមកលើកត្រពាំងថ្មហ្នឹង លើករយះពេលប៉ុន្មានទៅ?
អឿយ ពឿ:	លើករដូវប្រាំង។ ឲ្យតែរដូវប្រាំងប្រូតរួច គេឲ្យទៅលើក។
ឡុង ដានី:	រដូវប្រាំង ឲ្យទៅលើក!
អឿយ ពឿ:	រដូវប្រាំងឲ្យទៅលើក។
ឡុង ដានី:	រដូវវស្សាអត់ទេ?
អឿយ ពឿ:	រដូវវស្សាគេ ដល់ខែធ្វើស្រែ គេដកមកវិញ។

ឡុង ដានីៈ ដកទៅណាវិញ?

អឿយ ពឿៈ ដកមកឃុំយើងនេះវិញ ។ ដកមកឲ្យធ្វើស្រែនេះ ។

ឡុង ដានីៈ នៅឃុំម្កាក់វិញ?

អឿយ ពឿៈ នៅឃុំម្កាក់វិញ ។

ឡុង ដានីៈ អ៊ូ!ករុណា!

អឿយ ពឿៈ ដល់ពេលប្រមូលរួច បានគេឲ្យទៅទៀត គេឲ្យទៅលើកថែមទៀត ។

ឡុង ដានីៈ ទៅលើកហ្នឹង គេឲ្យតែយុវជន យុវនារីដែលកម្លាំងទី១ កម្លាំងពេញៗទេ? គេឲ្យ ...

អឿយ ពឿៈ មានអ្នកវ័យកណ្ដាលផង ។

ឡុង ដានីៈ វ័យកណ្ដាលទៀត?

អឿយ ពឿៈ វ័យកណ្ដាលផង ។

ឡុង ដានីៈ អើម!

អឿយ ពឿៈ វ័យកណ្ដាល យកតែប្រុសទេ ។

ឡុង ដានីៈ យកតែប្រុសទេ!

អឿយ ពឿៈ យកតែប្រុសៗ ។ ស្រីៗអត់ទេ ។

ឡុង ដានីៈ ហើយលើកហ្នឹង គេធ្វើផ្ទះធ្វើអីនៅអាងត្រពាំងថ្មឬក៏លើកពេលល្ងាចគេឲ្យមកភូមិមកស្រុកវិញ?

អឿយ ពឿៈ ធ្វើខ្ទម ធ្វើរោងរួចហើយ ។ រោងដេកដីណ៎ ។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ រោងផ្ទាល់ដី ។ គ្រាន់តែបាំងចំបើង បាំងស្បូវ ។ មានស្លឹក ១តូបប៉ុណ្ណេះៗទៅ ១ប្រឡោះៗ ប៉ុណ្ណេះទៅ ។ ម៉ាដេកៗទៅ ។

ឡុង ដានីៈ ហើយកាលហ្នឹង ព្រះអង្គ ដែលឮឈ្មោះ តា វ៉ាល់ ទេ?

អឿយ ពឿៈ តា វ៉ាល់! ចល័តតា វ៉ាល់ នៅចល័តតំបន់ ។ តា វ៉ាល់ក្ដាប់តំបន់នោះ ក្ដាប់ខាងអ្នកភ្នំពេញ អ្នកបាត់ដំបងទៅវិញ អ្នកដែលជម្លៀសមកណ៎ ។ គេហៅអ្នកថ្មី តា វ៉ាល់ក្ដាប់ពួកនោះឯង ។ នោះគេហៅថា ចល័តតា វ៉ាល់ ។

ឡុង ដានីៈ ចល័តតា វ៉ាល់!

អឿយ ពឿៈ ចល័តតំបន់ដែរ ។ នោះចល័តតំប់ដែរ គេហៅថាចល័តតំបន់ ។

ឡុង ដានីៈ ប៉ុន្តែ លោកតាកាលជិនាន់ហ្នឹងមិនមែននៅក្រោម តា វ៉ាល់ ទេ?

អឿយ ពឿៈ មិនទេ ។ នៅចល័តស្រុក ។

ឡុង ដានី៖ នៅចល័តស្រុក!

អឿយ ពឿ៖ នៅចល័តស្រុក ។

ឡុង ដានី៖ អញ្ចឹង ចល័តស្រុកគេឲ្យយើងទៅលើកដែរ?

អឿយ ពឿ៖ លើក ។ បើតា វ៉ាល់ ដាក់១ប៉ែក តា វ៉ាល់ ។

ឡុង ដានី៖ ដាក់មួយប៉ែក តា វ៉ាល់!

អឿយ ពឿ៖ ចល័តស្រុកដាក់មួយ មួយស្រុកៗ ៗ ៗដផ្លែគ្នា ។

ឡុង ដានី៖ ដល់ពេលចល័ត តា វ៉ាល់ ចល័តតំបន់ហ្នឹង ច្រើនពួកអ្នកមកពីភ្នំពេញ?

អឿយ ពឿ៖ អ្នកមកពីភ្នំពេញ ។ សុទ្ធតែអ្នកផ្សារ ។

ឡុង ដានី៖ សុទ្ធតែអ្នកផ្សារនៅភ្នំពេញ ។

អឿយ ពឿ៖ នេះអត់បាយ គ្រមែងគ្រមោង ។ អាត្មាក៏ជិតផាប់ម្ដងដែរណ៎ា រឿងចល័តណា ។ រឿងចល័តតំបន់ អាត្មាអង្គុយអញ៉ុះ គេដាំបាយបានគេដាក់ គេចាក់បាយសល់ គេចាក់ឡើងគំនរ អង្គុយទៅឡើងលិចក្បាលនោះ ។ ពួកចល័តដើរមក ដើរមកអញ៉ុះ ។ គ្នាស្គម ដើរមក ។ អាត្មាអង្គុយនោះឯង អាត្មាមិនដឹងរឿងនោះ ។ អាត្មាមិនដឹងរឿងទេ ។ ដល់នេះ ដើរមកដល់ថាបង បងខ្ញុំសុំបាយនេះទៅ ។ អាត្មាមិនដឹងរឿងនោះថា យកទៅបាយគេចាក់ចោល ។ គ្នាក៏រើសប្រកការុងៗ ៗ បែរជាចាក់ផ្កាប់ទុកនៅកៀនភ្លឺណ៎ា ។ អាត្មាទៅអង្គុយលើភ្លឺនោះឯង កៀនបាយនោះឯង ។ បាយក្ដាំងៗគេបាយស្ងួត បាយក្រៀម ។ អាត្មាថា យកទៅ មានណាគេទុកធ្វើអី ។ មានណានឹងស៊ី ។ ដល់គេយកទៅផុត ដល់មានអ្នកយកទៅផុត អាត្មាហ្នឹងហើយអ្នកទទួល ។ គេទិតៀនតាំងពីក្បាលនាយ ។

ឡុង ដានី៖ គេថាម៉េចទៅ?

អឿយ ពឿ៖ គេថា ឯងឲ្យបាយគេ ឯងមិនសួរគេ ឯងចេះឯងដឹង ។

ឡុង ដានី៖ ពីណាគេអ្នកទិតៀន?

អឿយ ពឿ៖ គេថា ឯងចេះឲ្យ ។ ហើយថា អាត្មានឹកហើបហើយណា ហើបថា ចេះឲ្យអីបាយទុកចោល ហើបហើយណា ប៉ុន្តែនឹកឃើញ ដូចជាទេវតាជួយអញ៉ុះឯង ។ អាត្មាបួសនេះ អាត្មាជឿបុណ្យណាស់ណ៎ា អាត្មាបួសបានយូរណាស់ណ៎ា ។ អាត្មាដូចជាស្អឹមកនាំមាត់អាត្មាឲ្យឈប់និយាយថា ខ្ញុំទទួលកំហុសហើយ ខ្ញុំខុសហើយ ខ្ញុំទទួលកំហុសហើយ ថ្ងៃក្រោយខ្ញុំឈប់ធ្វើហើយ ។ ប្រុងផាប់ប៉ុន្មានដងហើយ ប៉ុន្តែដូចស្អឹមកនាំមាត់អាត្មាអញ្ចឹងឯង ។ បានអាត្មាជឿថាដូចព្រះនេះឯង ។

ឡុង ដានីៈ អ្នកទិតៀនព្រះអង្គហ្នឹងជា....?

អឿយ ពឿៈ ជាប្រធានណា៎ៗ

ឡុង ដានីៈ ជាប្រធានចល័តស្រុកហ្នឹង ហើយក៏ .... ?

អឿយ ពឿៈ ទេ! ប្រធានយើង ប្រធានក្តាប់រួមយើងមួយឃុំហ្នឹងៗ ប្រធានក្តាប់រួមមួយឃុំៗ

ឡុង ដានីៈ អ៎ូ!

អឿយ ពឿៈ ប៉ុន្តែពួកហ្នឹង អ្នករាយការណ៍នោះៗ

ឡុង ដានីៈ អ្នករាយការណ៍!

អឿយ ពឿៈ ពួកហ្នឹង អ្នកសម្លាប់នោះៗ អាត្មាជឿថា ពួកនោះ អ្នកសម្លាប់ៗ បើពួកនោះមិនរាយការណ៍ មនុស្សអត់ងាប់ទេ ព្រោះថាសម័យនោះគេដាក់ក្នុង៣នាក់មួយពួកៗ ៣នាក់មួយពួកនេះ គេឲ្យតាមដានគ្នាៗ កន្លែងខ្លះ កន្លែងតាមដានគ្នាៗ ហើយបើយើង៣នាក់មួយពួក ៣នាក់នេះមិនត្រូវគ្នាៗ បានន័យថា វាមានមេពួក បើមេពួកវាគេរាយការណ៍ មេពួកគេរាយការណ៍ឲ្យមេក្រុម មេក្រុមគេរាយការណ៍ ឲ្យមេកងមេកងគេរាយការណ៍ឲ្យមេក្តាប់រួមៗ យើងទៅហើយ មិនបាននៅទេៗ

ឡុង ដានីៈ អើម!

អឿយ ពឿៈ មិនបាច់មានអ្នកមកពីភ្នំពេញណាមកចាប់ទេ តែគ្នាឯងនេះឯងចាប់នោះៗ

ឡុង ដានីៈ អញ្ចឹង! ហើយពួកអ្នកដែលកងចល័តមកពីភ្នំពេញមកលើកហ្នឹង ស្លាប់ច្រើនទេ?

អឿយ ពឿៈ ស្លាប់ច្រើនណាស់ៗ

ឡុង ដានីៈ ស្លាប់ដោយសារមូលហេតុអ្វី គេចាប់យកទៅ ឬក៏ដោយសារអត់ឃ្លាន?

អឿយ ពឿៈ ស្លាប់ទី១ អត់បាយៗ ទី២ ស្លាប់នៅកន្លែងធ្វើការ គ្នាមិនដែលធ្វើការអីណា៎ៗ ដើមដំបូងគេឲ្យទាញនង្គ័ល ទាញអីទៅណាៗ កន្លែងខ្លះឲ្យអូសនង្គ័លទៅៗ ដល់នេះ វាឡើយហើយណាៗ តាំងថាវិញហើយ ស្មានតែតមាត់បានៗ ថាវិញ ច្រើនតែគេចាប់វាយចោលនៅនោះឯងៗ គេថា មិនដែលមានអាណាមកធ្វើអញ្ចោ៎ះៗអញពីដើមក៏អញមិនបានមកធ្វើអញ្ចោ៎ះៗ ចេះតែស៊ីរស់ៗ គេចាប់ទៅៗ ហើយទី២ ខ្លះចង់តែគេពាក្យគេកុហកណាដែលគេថានយោបាយៗ អាត្មាដឹងថាពាក្យគេកុហកៗ ថានរណាណែ៎ បងប្អូនណាដែលពាក់សក្តិ២ សក្តិ៣អីណាៗ

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ ចង់បាន ចង់បានរួចខ្លួនណា៎ ចង្អុលថាលើក ថាពាក់សក្តិ២សក្តិ៣ៗ ល្ងាចឡើងគេចាប់ទៅស្ងាត់ច្រៀបអស់លីងៗ យកទៅវាយចោលអស់ៗ

ឡុង ដានី៖ ប៉ុន្តែកាលជំនាន់ហ្នឹង ពួកនិរតីអត់ទាន់មកទេ?

អឿយ ពឿ៖ ទេ! អត់ទាន់មកទេ។ កាលនោះ នៅពាយ័ព្យ។

ឡុង ដានី៖ ពាយ័ព្យ!

អឿយ ពឿ៖ នៅពាយ័ព្យ។ ពាយ័ព្យ។

ឡុង ដានី៖ ហើយលើកអាងត្រពាំងថ្មហ្នឹង លើកប៉ុន្មានដូចថា ខែប្រាំង១ ប៉ុន្មានប្រាំងទៅ បានចប់?

អឿយ ពឿ៖ ៣ប្រាំង។

ឡុង ដានី៖ ៣ប្រាំង!

អឿយ ពឿ៖ ៣ប្រាំង។ ៣ប្រាំងរួច។ រួចធ្វើស្រែប្រាំងទៀត។ បង្ហូសទាំងនេះទៀត .....

ឡុង ដានី៖ ធ្វើស្រែប្រាំងទៀត?

អឿយ ពឿ៖ អើម! អាត្មាទៅដេកធ្វើស្រែប្រាំងរួច។ ដល់ពេលធ្វើស្រែឆ្នាំក្រោយនេះ អាត្មាទៅធ្វើស្រែប្រាំងនោះ ក្របី៣០០នឹម។

ឡុង ដានី៖ អើម!

អឿយ ពឿ៖ ទៅវាអត់ណាស់ ស៊ីតែបបរ។ ដល់ពេលអត់ហើយ ប៉ុន្តែស្រែប្រាំងកើតណាស់។

ឡុង ដានី៖ កើត..?

អឿយ ពឿ៖ ក៏ប៉ុន្តែអត់បានបាយទេ។

ឡុង ដានី៖ ចុះបើកើតម៉េចបានអត់បានបាយ?

អឿយ ពឿ៖ ហ្នឹងបានថាហ្នឹង។ គេមិនឲ្យយើងនោះ គេមិនឲ្យបាយយើង។

ឡុង ដានី៖ ទៅណាទៅស្រូវអី?

អឿយ ពឿ៖ ហ៊ើ! ស្រូវអីយកទៅណា អាត្មាក៏មិនបានសួរគេ។ ប៉ុន្តែពួល្ងៀង១ ថា យកទៅចិន យកទៅអី។ អាត្មាក៏មិនបានដឹងទេ ប៉ុន្តែថា ពួថា ពួតែគ្នាឯងគេ និយាយថា យកទៅចិននេះ។ ដល់ថា យកទៅចិនធ្វើអីហ្ន៎? ថាយកដូរចបកាប់ថា ឯងឃើញចបកាប់អត់ ឯងមើលចបកាប់ហ្នឹងសុទ្ធមកពីចិនទៅ។ គ្នាឯងហ្នឹងថា ប៉ុន្តែ ........

ឡុង ដានី៖ ជំនាន់ហ្នឹង ដូចថា ដោយសារមានការអប់រំ ការអីអញ្ចឹង ដូចថាយើងអ្នកមូលដ្ឋាន ហើយជាមួយពួក១៧មេសា ពួកថ្មី យើងកាលហ្នឹងយើងមានអារម្មណ៍ ដូចថា ស្អប់គ្នាដែរអត់ទេ?

អឿយ ពឿ៖ ស្អប់។ មានអារម្មណ៍ថាស្អប់ ប៉ុន្តែ អ្នកខ្លះ បើដូចអាត្មានេះស្រណោះ ពីព្រោះអាត្មាស្គាល់ទីក្រុងភ្នំពេញមិនមែនទើបស្គាល់សម័យនេះទេ។ អាត្មាស្គាល់តាំងពីសម័យ

សាធារណៈរដ្ឋ ព្រោះអាត្មាស្រណោះៗថា រូបគេក៏ដូចរូបឯង។ ធ្លាប់ស៊ីធ្លាប់ចុក ឃើញឯង ចុះបើអាត្មាមិនស្រណោះ អាត្មាដែលហ៊ានឲ្យបាយក្តាំងគេ។ នឹកឃើញ អញ្ចេ៎ះ ទុកធ្វើអីបាយក្តាំង ឲ្យទៅ។ ដល់ឲ្យទៅ ឯងសឹងផាប់ជំនួសគេ។

ឡុង ដានី: បើសិនជាអ្នកផ្សេងៗ ដូចជា អ្នកមូលដ្ឋានផ្សេងៗ គេមានអារម្មណ៍ដូចថា ពួកខាងគេមានប្រាប់ថា ពួកទីក្រុងពួកហ្នឹង?

អឿយ ពឿ: ពួកអ្នកដែលមិនដែលដើរ ចោទពួកនោះថា ជិះជាន់កម្លាំងឯង ជិះជាន់ពលកម្មឯង ស៊ីដោយសារឯង ព្រោះពួកនោះសុទ្ធតែពួកល្ងង់ហ្នឹង។

ឡុង ដានី: ករុណា!

អឿយ ពឿ: ហើយសុទ្ធតែពួកល្ងង់។ អត់ចេះពិចារណាថា គេនៅផ្សារគេខំមុខរបរគេខាងផ្សារ វាអត់អញ្ចេ៎ះទេ។ ដល់ទៅពួកគេ គេថា នយោបាយគេ គេបោកប្រាស់ គេថា ពួកនោះ ពួកនាយទុន ពួកសក្តិភូមិអី ជិះជាន់កម្លាំងឯងអី។ ឡានក៏ឡានឯង ម៉ូតូ ក៏ម៉ូតូឯង។ ដល់ចុងក្រោយ មានអីណា៎។

ឡុង ដានី: ករុណា!

អឿយ ពឿ: ហើយថាយ៉ាងម៉េច គ្រាន់តែអាត្មានៅវាយអន្លប់ខាងលិច តាម៉ា។ គ្នា៣០នាក់។ រត់មក គ្នា៣០នាក់ យោធាម្នាក់ឯង។ កាំភ្លើង អ៊ីមស៊ី មួយដើមបាញ់ដួលទ្រាំងៗ ៗ អាត្មាញ័រអស់។

ឡុង ដានី: ពីណាបាញ់ហ្នឹង?

អឿយ ពឿ: ពួកយោធាបាញ់។ បាញ់អ្នករត់ទៅថៃហ្នឹង។

ឡុង ដានី: យោធា ពេលដែលយើងរត់ទៅថៃទៅ គេបាញ់?

អឿយ ពឿ: ហ្នឹងហើយ គេបាញ់។ អាត្មាវៃអន្លប់រួច អាត្មាដឹកក្របីឲ្យស៊ី។ ដឹកក្របីឲ្យស៊ីទៀត។

ឡុង ដានី: នៅណាហ្នឹង នៅម្តុំណា?

អឿយ ពឿ: នៅម្កាក់នេះ។ នៅខាងជើង តាម៉ា។

ឡុង ដានី: ខាងជើង តាម៉ា!

អឿយ ពឿ: ខាងជើងតាម៉ា។ អាត្មាធ្វើស្រែប្រាំងនៅនោះឯង។

ឡុង ដានី: ហើយអ្នករត់ទៅថៃហ្នឹង អ្នកណា?

អឿយ ពឿ: មិនដឹងប្រជាជនមកពីខាងណា។

ឡុង ដានី: អ្នកប្រជាជនមូលដ្ឋាន ឬក៏ .........?

អឿយ ពឿ: មូលដ្ឋាននេះឯង។

ឡុង ដានី៖ មិនមែន១៧មេសា?

អឿយ ញឿ៖ ទេ! មិនមែនទេ។ ពួកមូលដ្ឋាននេះឯង ព្រោះសុទ្ធតែខ្មែរ។ អាត្មាថា ខ្មែរម៉េចក៏វាមិនកាប់។ កាលហ្នឹង បើកាប់បានសាប់នេះឯង កាលជិនទាន់ហ្នឹងណា ព្រោះ៣០នាក់។

ឡុង ដានី៖ ៣០នាក់ ហើយយោធាប៉ុន្មាននាក់?

អឿយ ញឿ៖ ម្នាក់ៗ ដឹងថាសល់៣គ្រាប់ប៉ុណ្ណោះឯង។ បើចែកគ្នាវត់កាប់ បានបាត់។ អាត្មាញ័រដៃ អាត្មានៅដើងទេអីចេះ ដល់បាញ់រួចដើរតម្រង់អាត្មានេះឯង។

ឡុង ដានី៖ ពួកយោធាតម្រង់មកព្រះអង្គ?

អឿយ ញឿ៖ មកដើរតម្រង់មក ឲ្យអាត្មាយកក្របីទៅអូស។ យកទៅចោលឲ្យផុតស្រែ។

ឡុង ដានី៖ យកទៅអូសសពដែលគេបាញ់?

អឿយ ញឿ៖ ហ្នឹងហើយ ខ្មោចហ្នឹង។

ឡុង ដានី៖ ប៉ុន្មាននាក់?

អឿយ ញឿ៖ ៣០។

ឡុង ដានី៖ ៣០!

អឿយ ញឿ៖ ៣០។

ឡុង ដានី៖ សាប់ទាំង៣០?

អឿយ ញឿ៖ សាប់ទាំង៣០។

ឡុង ដានី៖ អូសយកទៅណាទៅ?

អឿយ ញឿ៖ អូសយកទៅខាងភ្លឺដែលគេស្ទូង។ ភ្លឺខាងលិច ភ្លឺព្រំដែនអញ្ចេះ។

ឡុង ដានី៖ នៅខាងភូមិ តាម៉ា ហ្នឹងដែរ?

អឿយ ញឿ៖ ហ្នឹងហើយ នៅខាង ឆ្ងាយដែរ ឆ្ងាយពីតាម៉ា

ឡុង ដានី៖ នៅជិតម្កាក់ដែរ?

អឿយ ញឿ៖ គេហៅថាព្រៃឬស្សីខុប .....

ឡុង ដានី៖ ប៉ុន្តែនៅក្នុងភូមិម្កាក់ហ្នឹងដែរ?

អឿយ ញឿ៖ នៅភូមិម្កាក់។

ឡុង ដានី៖ ករុណា!

អឿយ ញឿ៖ អាត្មាអូសទៅ អូសទៅផុត។ ខ្មោចផង អីផង។ ដាក់ចោលទៅ វាខ្មោចខ្មោចនោះ។ វាមិនដល់ខ្មោចគេទេណា ចាញ់ខ្មោចមនុស្ស។ ខ្មោចមនុស្សហ្នឹង ខ្លាំងជាងខ្មោចខ្មោច។

ឡុង ដានី៖ ហើយព្រះអង្គ បន្ទាប់ពីលើកអីនៅត្រពាំងថ្មហើយ គេផ្លាស់ទៅណាទៀតទៅ?

អឿយ ពឿ៖ មកនេះហើយ ៗ មកនេះវិញ ៗ មកឃុំនេះវិញ គេយកទៅឲ្យធ្វើស្រែប្រាំងឯនោះវិញ ៗ

ឡុង ដានី៖ នៅណាវិញ?

អឿយ ពឿ៖ នៅត្រពាំងថ្ម ៗ គេហៅរំចេក ប្រឡាយរំចេក តាមប្រឡាយរំចេកដល់នៅព្រៃមាន់នោះ ៗ ពួកអាត្មានេះឯង អ្នកធ្វើ ៗ

ឡុង ដានី៖ ធ្វើនៅព្រៃមាន់វិញ?

អឿយ ពឿ៖ ហ្នឹងហើយ! ធ្វើនៅព្រៃមាន់ ៗ ដល់ពេលក្រោយមក បានគេដកអាត្មា ដកអាត្មាមកនៅឃុំវិញ នៅតាមឃុំវិញ ៗ

ឡុង ដានី៖ ឃុំណាវិញ?

អឿយ ពឿ៖ ឃុំម្កាក់ ៗ ដល់ថ្ងៃនោះ អាត្មាក៏គោះៗដី គេហៅថា គោករល្បើកតែឯង គាស់ចំការណ៉ា ៗ កាលហ្នឹង និរតីចូលមកហើយ ៗ

ឡុង ដានី៖ និរតីចូលមក?

អឿយ ពឿ៖ និរតីចូលមកហើយ ៗ

ឡុង ដានី៖ ពេលដែលព្រះអង្គ មកធ្វើស្រូវប្រាំងនៅត្រពាំងថ្ម មកធ្វើស្រែអី មកព្រៃមាន់អីហ្នឹងនិរតីចូលមកនៅ?

អឿយ ពឿ៖ ចូលមកហើយ ៗ

ឡុង ដានី៖ ករុណា!

អឿយ ពឿ៖ ចូលមកខាងនិរតីម្ដងហើយម្ដងនេះ ៗ និរតីក្ដោបក្ដាប់ម្ដងហើយ ៗ ដល់និរតី គេឃើញអាត្មាស្គម គេក៏ទៅជួយគាស់ ៗ ជួយគាស់រាល់ថ្ងៃ ជួយគាស់រាល់ព្រឹក ជួយគាស់គល់ ៗ

ឡុង ដានី៖ ពួកនិរតីហ្នឹងមកជួយគាស់?

អឿយ ពឿ៖ ហ្នឹងហើយ ជួយគាស់ ៗ

ឡុង ដានី៖ ពួកនិរតីធ្វើអ្វីបានគេមកជួយគាស់?

អឿយ ពឿ៖ មេ ៗ គេមេនោះ ៗ

ឡុង ដានី៖ មេ?

អឿយ ពឿ៖ គេមេក្ដាប់ឯង ៗ

ឡុង ដានី៖ មេក្ដាប់ខាងអ្វីគេ ខាងកងចល័ត?

អឿយ ពឿៈ ក្តាប់ខាងយុវជន។

ឡុង ដានីៈ ខាងយុវជន!

អឿយ ពឿៈ ខាងយុវជន។ គេមកជួយគាស់។ គេស្រណោះអាត្មា គេមកជួយគាស់។ គេឃើញអាត្មាធ្វើការមិនដែលខាននោះ។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ ហ៊ានខានណា។ បើប្រវត្តិ គេហៅថា ប្រវត្តិអាក្រក់នោះ។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ ឱវត់ទៅថៃនោះ។

ឡុង ដានីៈ អញ្ចឹង ពួកនិរតីដែលមកក្តាប់នៅកងព្រះអង្គឈ្មោះអ្វីទៅ?

អឿយ ពឿៈ ឈ្មោះ សែត។

ឡុង ដានីៈ ឈ្មោះ សែត ក្តាប់ខាងយុវជននៃ ..... ?

អឿយ ពឿៈ នារីនៅម្កាក់។ ក្តាប់យុវជននារីនៅម្កាក់។

ឡុង ដានីៈ នៅម្កាក់?

អឿយ ពឿៈ នៅម្កាក់។

ឡុង ដានីៈ អញ្ចឹង! កាលពីនិរតីមក នៅម្កាក់ហ្នឹងគណៈឃុំឈ្មោះអ្វីទៅ?

អឿយ ពឿៈ ឈ្មោះ ផាត។

ឡុង ដានីៈ ឈ្មោះ តា ផាត?

អឿយ ពឿៈ ឈ្មោះ តា ផាត។

ឡុង ដានីៈ តា ផាត គាត់ .....

អឿយ ពឿៈ ខ្វាក់ភ្នែកមួយចំហៀង!

ឡុង ដានីៈ ខ្វាក់មួយចំហៀងហ្នឹង?

អឿយ ពឿៈ ហ្នឹងហើយ។

ឡុង ដានីៈ អ៊ឹម! ប្រពន្ធគាត់ឈ្មោះ ផល ហ្នឹង?

អឿយ ពឿៈ ប្រពន្ធមិនស្គាល់ទេ។ អាត្មាមិនដែលហ៊ានសួរឈ្មោះគេទេ។ អាត្មាខ្លាចណាស់។

ឡុង ដានីៈ តា ផាត។

អឿយ ពឿៈ គេថា បង ផាតៗ ក៏ស្គាល់គេទៅ។ ចំណាំបាន។

ឡុង ដានីៈ កាលហ្នឹង គាត់គណៈឃុំម្កាក់។ ហើយ គណៈស្រុកសេរីសោភ័ណ្ឌឈ្មោះអ្វីទៅពួកនិរតី?

អឿយ ពឿៈ មិនដឹងទេ ៗ អាត្មាមិនដឹងទេ ៗ តែដល់ប៉ុណ្ណោះហើយ អាត្មាមិនដឹងទេ ៗ

ឡុង ដានីៈ ហើយដល់ពេលផុតពី តា ហឹង តាអីទៅ ៗ គណះតំបន់មកពីខាងនិរតី ?

អឿយ ពឿៈ អាត្មាលែងស្គាល់ហើយ ៗ

ឡុង ដានីៈ លែងស្គាល់ហើយ ៗ

អឿយ ពឿៈ លែងស្គាល់ហើយ ៗ

ឡុង ដានីៈ ស្គាល់តែ តា ផាត ទេ?

អឿយ ពឿៈ ស្គាល់តែមេឃុំដែលនៅជិត ដែលនៅម្កាក់នោះឯង ៗ

ឡុង ដានីៈ ចុះមេឃុំទឹកថ្លា?

អឿយ ពឿៈ មេឃុំទឹកថ្លាក៏អាត្មាមិនដែលស្គាល់ ៗ មិនដែលស្គាល់ទេ អាត្មាមិនដែលទៅណាទេ ៗ

ឡុង ដានីៈ ស្គាល់តែ តា ផាត?

អឿយ ពឿៈ ស្គាល់តែ តា ផាត ៗ សែត និរតី ៗ ប្រធានសហករណ៍នៅភូមិអាត្មានោះ ឈ្មោះ ដួន ឈ្មោះ តា ណូក ៗ

ឡុង ដានីៈ ហើយពេលចេញពីម្កាក់ហ្នឹង គេឲ្យទៅធ្វើការរហូតដល់ព្រៃមាន់?

អឿយ ពឿៈ ទៅតើ ទៅនោះ ៗ

ឡុង ដានីៈ ព្រះអង្គមានពុទ្ធដីកាមុនហ្នឹងថា ពេលដែលទៅព្រៃមាន់ហ្នឹង យ៉ាងម៉េចបានគេឲ្យព្រះអង្គ ឲ្យខាង ?

អឿយ ពឿៈ ធ្វើស្ពាននោះ ៗ

ឡុង ដានីៈ ទៅធ្វើស្ពាន?

អឿយ ពឿៈ អញ៉ុះ! ថ្ងៃនោះ វាភ្លៀង ៗ ភ្លៀងអាត្មាទទឹកអស់លីង ៗ តាំងពីហ្នឹងមក អាត្មាមិនដែលបានបើកខោបើកអាវអីគេណាមួយគេទេ ៗ ហើយ ក៏វាអត់ខោ វាអត់ខោស្លាប់ណា ៗ អត់ខោខ្ទី ក៏មេកងគេដឹងនេះ មេកងគ្នាឯងនោះ វាត្រូវគ្នានោះ ៗ ថា អាមាពឿ ឯងអត់មានខោខ្ទីទេ? ទេ! អញមិនដែលមានខោខ្ទីឯណា ឯងមិន ដែលបើកឲ្យអញណ៉ុះ ៗ ចេះនិយាយ 'អា' គ្នាឯង ណា ៗ

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ ដល់ល្ងាចគេប្រជុំ ៗ ដល់គេប្រជុំ មេគេ មេកងធំគេធ្វើការអឺចប់ ៗ បានសេចក្ដីផ្សេងៗណា បានលើកឡើង ខ្ញុំសូមឡើងចាប់អារម្មណ៍ ខ្ញុំគ្មានបញ្ហាអ៊ីទេ ខ្ញុំសុំស្នើខោឲ្យអាមិត្តនេះមួយ ៗ

ឡុង ដានីៈ ពីណាគេហ្នឹង? ឈ្មោះអ៊ី?

អឿយ ពឿ: អាហ្នឹង មេកង ឈ្មោះឈួយ ។ ឈ្មោះ អាឈួយ ។ នៅសព្វថ្ងៃនេះឯង វាណា៎ ។

ឡុង ដានី: ឈួយ!

អឿយ ពឿ: ឈួយ ។ ឈ្មោះ ឈួយ ។

ឡុង ដានី: គាត់នៅណាឥឡូវ?

អឿយ ពឿ: នោះនៅបែកចាននោះឯងសព្វថ្ងៃ ។ ភូមិបែកចាន ។

ឡុង ដានី: ភូមិបែកចាន ។

អឿយ ពឿ: ហ្នឹងហើយ ភូមិបែកចាន ។

ឡុង ដានី: ភូមិបែកចាន ឃុំម្កាក់ដែរ?

អឿយ ពឿ: ហ្នឹងហើយ ។

ឡុង ដានី: ឈ្មោះ ឈួយ ។

អឿយ ពឿ: ឈ្មោះ ឈួយ ។ មេក្ដាប់រួមនោះគេថា មេក្ដាប់រួមនោះ ប៉ុន្តែវាងាប់ហើយសព្វថ្ងៃនៅគោកគោ ឈ្មោះវា អា ណាន់ ។ ថាម៉េចក៏មិនដែលធ្វើការ វាថាអញ៉ុះ ។

ឡុង ដានី: ករុណា!

អឿយ ពឿ: អាត្មា ដូចជាស្ទើមកបាំងមុខនោះឯង ។ ខឹងដល់ធ្វើការរាល់ថ្ងៃ ខឹងក្រោកគ្រូស ក្រវាត់បង់ក្បិនកន្ទេងអញ៉ុះ មិត្តឯងមិនអីបានឃើញខ្ញុំ បើមិត្តឯងរវល់តែឆ្មាំងបាយនោះ ។ ថាអញ៉ុះ មិត្តឯងមិនដែលទៅកន្លែងធ្វើការអី បានអីហ្នឹងឃើញខ្ញុំ មិត្តឯងនៅឈ្បលតែចង្ក្រានបាយនោះ ។ គេស្ទុះហ៉ោមក អានិរតីកាន់រនាស់ដែកនោះ គេចូលធ្វើ ... រាល់ថ្ងៃនេះ មិត្តឯងឈប់ មិត្ត ណាន់ មិត្តឯងខុសហើយ ។ មិត្តឯងបើកឲ្យគាត់ក៏បើកឲ្យទៅ ។ មិត្តឯងមិនបើកឲ្យគាត់ ចុះមិត្តឯងចាំបាច់ថាឲ្យគាត់អី ។ ណែ៎ ពឿណា៎ ខ្ញុំជួយគាស់រាល់ថ្ងៃ ។ ខ្ញុំទៅមិនជួយគាស់ណាគេទេ ខ្ញុំជួយ គាស់តែមិត្តពឿនេះឯង ។ ដល់ពេលនេះ គេដាក់ឈ្មោះ អាត្មា ។ គេហៅឈ្មោះ អាត្មាមក ។ ព្រឹកឡើងគេហៅឈ្មោះ អាត្មាមក ។ អាត្មាថា ងាប់បាត់ ។ អាត្មាថា អាត្មាងាប់បាត់ ។ គេដកមកតែឯង មកពីចំការគាស់នេះ ។ កំពុងតែគាស់ៗ គេហៅអាត្មាមក អាត្មា ថាងាប់បាត់ ។ អាត្មាងាប់ហើយ ។

ឡុង ដានី: គេហៅពីកន្លែងចំការនៅណា?

អឿយ ពឿ: នៅល្បើកនេះឯង គេហៅមកកន្លែងនៅតាម៉ា គេឲ្យទៅនៅតាម៉ា ។

ឡុង ដានី: ករុណា!

អឿយ ពឿៈ មកដាំបាយនៅតាម៉ានេះៗ អាគ្នាមកដល់ ពួកម៉ាកនោះវាធ្វើចុងភៅ ប៉ុន្តែអានោះនៅកំពង់ចាមៗ ឈ្មោះវាអា ថៃស៊ីនៗ អានោះ បើសព្វថ្ងៃគេថាមនុស្សខ្មៅយណាៗ

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ សព្វថ្ងៃគេថាមនុស្សខ្មៅយៗ វាចេះដាំ ចេះស្ល គេឲ្យវាដាំបាយៗ ដល់នេះមកដល់ វាដួសបាយឲ្យអាគ្នាទៅៗ ឯងដួសបាយឲ្យអញស៊ីនេះ ឲ្យអញស៊ីផ្តាំងាប់ហើយ អាថៃស៊ីនៗ ឯងអត់ងាប់ទេ វាថាអញ្ចឹងៗ វានិរតី វានិយាយៗ អ៊ូ! ណែ! វាកំពង់ចាមៗ ឯងអត់ងាប់ទេ គេយកឯងឲ្យទៅបើកឡាន បើកឡានដឹកអំបិល ប្រាប់អញឲ្យត្រង់មក អញមុខតែងាប់ហើយៗ ថាងាប់ក៏ងាប់ទៅចុះ មិនសុខចិត្តរត់ទេ តែរត់ទៅអស់មួយគ្រួសារទៀត អស់ទាំងម៉ែ អស់ទាំងប្អូនៗ នឹកឃើញងាប់ក៏ងាប់ទៅ វាដល់កំណត់ទៅហើយណាៗ

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ មួយសន្ទុះឃើញគ្នាមក១០នាក់ទៀតៗ មក១០នាក់ទៀត គេថា មើលមានទៅតែឯងណាៗ ចុះម៉េចគេឲ្យអញមកមុនគេអញ្ចឹងៗ គេមិនទាន់រៀបឈ្មោះបានៗ ថាបានមក១០នាក់ទៀត បានដឹងថា អ៊ូ!មិនងាប់ទេៗ បានគេឲ្យដើរទៅស្វាយទៅដេកនៅចំការខ្នុរៗ កន្លែងទទួលភ្ញៀវគេនៅស្វាយៗ

ឡុង ដានីៈ ពីណាគេឲ្យមកហ្នឹង?

អឿយ ពឿៈ មេគេនៅស្វាយនោះឯងៗ គេហៅ គេឲ្យមេនេះបញ្ជូនកម្លាំងទៅគេនោះៗ គ្នា១០នាក់ៗ ៨ឆ្នាំង លេខ៨ៗ អាគ្នារាប់ច្បាស់ គ្នា១០នាក់ បាយ៨ឆ្នាំង លេខ៨ អត់ឆ្អែតទេៗ

ឡុង ដានីៈ ឆ្នាំងលេខ៨ ១ឆ្នាំងៗ

អឿយ ពឿៈ ឆ្នាំងលេខ៨ ១០នាក់ៗ ១០នាក់ ៨ឆ្នាំង លេខ៨ អាគ្នារាប់ គេដាក់ដង្ហែររៀបអញ្ចោះ មានទុកបាយអាគ្នារាប់ៗ ចាំមើលអាគ្នារាប់មើល អាគ្នារាប់មើល ដល់អាគ្នារាប់មើល ពួកគេពោល ពួកអាចុងភៅនោះពោលថា ឯងដាំល្មមថាសល់ច្រើនដែរ ហេតុអីបានពូៗគាត់ហូបច្រើនម៉េស? ថាអញ្ចឹងបានគាត់ស្គមៗថា! អាអ្នកនៅក្នុងនោះមិនដឹងអីៗ មិនដឹងទេ មិនដឹងថាអ្នកនៅណោះអត់ទេ ចុះវាមានបាយស៊ីនោះ វាធាត់ឡើងកន្ទុលៗ ៗ

ឡុង ដានីៈ ពួកនិរតីណែ?

អឿយ ពឿៈ ហ្នឹងហើយៗ វាថាឯងស្រួលនោះៗ វាឆ្ងល់ថា ម៉េចក៏ហូបច្រើនម៉េសពូៗនេះៗ

ឡុង ដានីៈ មួយឆ្នាំង អស់ម្នាក់ ។

សុខ វណ្ណៈ ចង់អស់មួយឆ្នាំង ។

អឿយ ពឿៈ ចង់អស់មួយឆ្នាំង ។

ឡុង ដានីៈ ម្នាក់?

អឿយ ពឿៈ ម្នាក់ ។

ឡុង ដានីៈ អញ្ចឹង ១០នាក់ ៨ឆ្នាំង ។

អឿយ ពឿៈ ៨ឆ្នាំង ។ ១០នាក់ ៨ឆ្នាំង ។

ឡុង ដានីៈ ឆ្នាំងលេខ៨?

អឿយ ពឿៈ ឆ្នាំងលេខ៨ ។

ឡុង ដានីៈ ប៉ុន្មានកំប៉ុងទៅឆ្នាំងលេខ៨?

អឿយ ពឿៈ មិនដឹងប៉ុន្មានទេ ប៉ុន្តែដឹងតែឆ្នាំងលេខ៨ ។ អាត្មាឮគេនិយាយអញ្ចឹង អាត្មាឆ្អែតមុនគេ ។ អាត្មាឆ្អែតមុនគេ ដល់មួយសន្ទុះ ពួកអ្នកមិនបានឮ វាទៅថែមៗ អត់ ។ វាថាអស់ហើយពូ អស់ហើយពូៗ ។ ដើរមកដល់ ដេកនៅវត្តចំការខ្នុរអាខ្វះពោល ។

ឡុង ដានីៈ ឆ្អែតពេក?

អឿយ ពឿៈ មិនទាន់ហ្នឹងឆ្អែតផង វាថា ។ វាថា មិនទាន់ហ្នឹងឆ្អែតផង ។ ឆ្ងាញ់អើយឆ្ងាញ់ ។ ប៉ុន្តែអត់មានហូបអីទេនេះ អម្ពិលខ្ទិះយើងហ្នឹង និងទឹកស៊ីអៀវ ក៏ដាក់ម្ទេសខ្ទិះ ។ អ៊ូយ! និយាយពីឆ្ងាញ់ ។

ឡុង ដានីៈ អម្ពិលទឹកស៊ីអៀវសោះ?

អឿយ ពឿៈ ហ្នឹងហើយ ។ អាត្មាកើតទាន់ហើយ ។ អាត្មាកើតទាន់ កាលសម័យនោះ ក៏វាទាន់ ដូចជាថា ដូចគេថាគុកអត់ជញ្ជាំង ។ វាមិនបានដឹងរឿងឆ្ងាយទេ វាដឹងតែរឿងមួយកន្លែងឯងនៅកន្លែងឯង ឯងនៅត្រឹមណា ដឹងតែត្រឹមនោះ ។

ឡុង ដានីៈ ពេលដែលគេឲ្យមកស្វាយហ្នឹងនៅឆ្នាំណាទៅ?

អឿយ ពឿៈ ថាឆ្នាំ៧៧នេះឯង ។

ឡុង ដានីៈ ៧៧!

អឿយ ពឿៈ ៧៧

ឡុង ដានីៈ ករុណា! មកស្វាយ បាយហើយអីហើយ ធ្វើម៉េចទៀតទៅ?

អឿយ ពឿៈ ព្រឹកឡើងតាមថ្នល់ទៅព្រៃមាន់ ។ ព្រឹកឡើងគេយកឡានមកដាក់ រួចហើយចុះតាមស្ពាន ។ ១ស្ពាន គេបំបែក៥នាក់ ហើយអាត្មាទៅនោះ៥នាក់ ។

ឡុង ដានី៖ ធ្វើស្ពានណាហ្នឹង?

អៀយ ពឿ៖ ស្ពានចាប់ពីស្វាយទៅ។

ឡុង ដានី៖ ករុណា!

អៀយ ពឿ៖ ចាប់ពីស្វាយទៅ ប៉ុន្តែកន្លែងណាខ្ទះកម្ទាំងរហូតដល់សាលាក្រៅ អាត្មាចុះទៅនៅអឺមុនដំបូងទៅបៀតឆ្នូ។

ឡុង ដានី៖ ករុណា! បៀតឆ្នូ!

អៀយ ពឿ៖ ហ្នឹងហើយ បៀតឆ្នូមានស្ពានមួយ។ ទៅគេខ្ទះកម្ទាំងគេឲ្យអាត្មាទៅនោះ។ ទៅដល់បៀតឆ្នូ បូមទឹក បូមអ៊ីរួច។ ចាក់ថ្នឹមឲ្យគេរួច អីគេរួច។ គេបញ្ជូនទៅព្រៃមាន់។ គេបញ្ជូនទៅព្រៃមាន់បានបូមស្ពាននៅព្រៃមាន់។ ស្ពាននោះបូមទ្រីបានមួយឡានត្រាវ៉ូត្រីតានេល។

ឡុង ដានី៖ ត្រីតានេល!

អៀយ ពឿ៖ អើម! ត្រីតានេល។

ឡុង ដានី៖ ដូចត្រីឆ្លាំង?

អៀយ ពឿ៖ ហ្នឹងហើយ! បូមបានមួយឡានត្រាវ៉ូ។ អត់បានហូបទេ។ ថ្ងៃនោះ ថ្ងៃដែលស្រុកយើងបានរំដោះ។ ថ្ងៃនោះឯង ថ្ងៃបូមត្រីនោះខះ។ ពួកតាឈឿន មេនោះឯង គាត់ឃើញអាត្មាធ្វើការជាងគេ គាត់ស្រណោះអាត្មា គាត់ឲ្យវិទ្យុមួយ។ ថាមិត្តឯងយកវិទ្យុនេះស្តាប់មើលទៅ មិត្តឯងមិនបាច់លើកដីទេ។ មិត្តឯងគ្រាន់តែអង្គុយគោះបង្គីឲ្យគេទៅបានហើយ។ ហើយមើលម៉ាស៊ីន ម៉ាស៊ីន២គ្រឿង ម៉ាស៊ីនបូមទឹក។ ម៉ាស៊ីនបូមទឹកនេះ បើថាយ៉ាងណាៗ ឆាប់ប្រាប់គេ ឲ្យគេរៀបចំ។ គេឲ្យអង្គុយ។ គេមិនឲ្យឈប់ធ្វើការអ៊ីទេ។ គេគ្រាន់តែឲ្យអង្គុយវៃដីដែលជាប់បង្គី។ វៃដីឲ្យគេ។ ធ្វើការមិនដែលឈប់នោះ។ ហើយអាត្មាយប់អញ្ចោះ ដែលបូមត្រីនោះ គេតាមដានអាត្មាមើលឃើញអាត្មាទៅថែមិនឲ្យទឹកវាបាក់ណា៎។ អាត្មាគិតឃើញថា បើអាត្មាមិនថែបាក់មកយ៉ាប់ទៀត។ អាត្មាទៅថែនោះឯង ថែទឹកបិទ ថែបិទៗ។ ដល់នេះគេលបមើលអាត្មាគេថា អាត្មានេះមនុស្សសកម្ម។ អាត្មាអត់មានចង់ធំ ចង់អីទេ។ ប៉ុន្តែថា ដឹងថាបើសិនឯងមិនមើលទេ បាក់មក ឯងនឹងឯងទៀត។ ពួកគ្នាអ្នកនោះគ្នាដេកបាន បេះតែដេកងើកងោកៗទៅ។ ដល់ទៅនេះទៅ បានគេឲ្យវិទ្យុទៅដល់អាត្មា។ ដល់ព្រឹកឡើងគេដឹកឡានមក គេដឹកត្រីទម្លាក់ ឡានត្រីនោះណា៎ មិនបានស៊ីនោះទេ បានអាត្មា២នាក់ប្រធានកងនៅភ្នំស្រុក ប៉ុន្តែភ្លេចឈ្មោះគេ។ បានត្រីម្នាក់មួយ។ អញ្ចោះ! បាន

យប់ឡើងភ័យខ្លាចបាក់ ដាស់មេកងថា ណែ៎បង! គោះក្រោកទៅមើលស្ពានៗ មើលស្ពានឯណា ថាខ្លាចវាបាក់ តែវាបាក់ ពិបាកនរណា ពិបាកយើងនេះឯង។ បានទៅដល់នោះ ដល់ស្ពានឃើញត្រីៗ ត្រីវាខះហើយនោះ ត្រីវាឡើងមកៗ ថាតាដុតភ្លើងទៅ អាត្មាថា មានអីដុតភ្លើង កាប់សសរស្ពានដុត ពុះសសរស្ពាននេះដុតដាំបាយៗ គេទៅយកអង្ករមកដាំបាយបានមួយកាម៉ែល ត្រីម្នាក់មួយ អាត្រីតានេលនេះ អាំងត្រីតានេលៗ ហូបតែបាយរួចនាំគ្នាចងអង្រឹងបាន នាំគ្នាដេក ដល់ដេក តាឈឿនគាត់ក្រោកមក គាត់ថា អុញ! មកសំរាក់អីអញ្ចឹងក្រោកឡើងៗ ថ្ងៃហ្នុង គេអត់ឲ្យធ្វើការទេ ថ្ងៃនោះណា អាត្មាគេអត់ឲ្យធ្វើការទេ គេឲ្យនាំគ្នាដេកទៅៗ អ្នកពីរនាក់នេះអត់ឲ្យធ្វើការទេៗ ដល់ល្ងាចឡើង អាត្មាបើកវិទ្យុព្ទតែម្តង បនប៉ុល ពត ស្ទីណាណីៗ គាត់ព្ទថាអញ្ចឹង គាត់មករត់យកវិទ្យុពីអាត្មាវិញ ថាឈប់ស្តាប់ទៅ អត់កើតទេថាអញ្ចុ៎ះៗ កុំនិយាយណា ឯងព្ទ ព្ទតែឯងទៅៗ មិនឲ្យនិយាយប្រាប់គ្នាឯង ដែលមិនបានស្តាប់ណា មិនឲ្យប្រាប់ទេៗ អង្កុយៗពីនាក់មេកងថា យី! យ៉ាងណាទៀតហើយស្រុកនេះយ៉ាងណាទៀតហើយ បន ប៉ុល ពត អៀង សារី ខៀវ សំផន អីណាទៀតហើយៗ កើតរឿងទៀតហើយ មួយសន្ទុះឃើញឡានតែម្តង គឺបកាប់ៗៗៗៗ តាមការពិតកន្លែង តាឈឿន នេះឯងធំមើលទៅ ព្រោះដឹកអីវ៉ាន់ ដឹកប្រពន្ធទ័ពមកដាក់នោះឯង ឡើងណែន អត់បានបាយមួយថ្ងៃៗ អត់មានបាយទេ មួយថ្ងៃៗ អត់មានបាយចូលពោះ១គ្រាប់ទេថ្ងៃនោះៗ គេមិនឲ្យអង្ករទេៗ ថ្ងៃហ្នុងដាច់បាយប៉ត់ៗ មួយថ្ងៃណា គេហូបតែគ្នាគេទៅ គេអាលែងភ័យតែគ្នាគេដឹង បានគេមិនឲ្យឯងស៊ីៗ ដល់ថ្ងៃ ដល់ល្ងាចបានស្វាត់អស់ៗ ស្វាត់អស់ ចល័តឡើងមកពីប្រូតៗ ពួកចល័ត ពួកខាងអ្នកប្រូតៗ មកដល់មកជុំគ្នានោះ មកជុំ ថាយើងបានបាយអីហូបនោះ និយាយៗ ថាគេទៅអស់ហើយ គេទៅអស់ហើយ នោះស្រូវៗ មានអី នាំគ្នាបែនក៏បែន បុកក៏បុក កិនក៏កិន បានហូបនោះឯងៗ

ឡុង ដានីៈ ចុះព្រះអង្គ ពេលណាដែលព្រះអង្គទៅ បានទៅមើលភ្នំទ្រយោង?

អៀយ ពឿៈ ពេលដែលនៅព្រៃមាន់នោះអីៗ

ឡុង ដានីៈ ពេលទៅព្រៃមាន់ហ្នឹងឆ្នាំប៉ុន្មាន ដែលព្រះអង្គបានទៅមើល?

អៀយ ពឿៈ ឆ្នាំ៧៧ៗ

ឡុង ដានីៈ ៧៧ ខែ ប្រហែលជាខែប្រាំង ឬក៏ខែវស្សាកាលហ្នឹង?

អៀយ ពឿៈ ទេ! ខែប្រាំងៗ

ឡុង ដានី:	ខែប្រាំង ។

អឿយ ពឿ:	ខែប្រូតនេះឯង ។

ឡុង ដានី:	ខែប្រូត!

អឿយ ពឿ:	ខែប្រូតរួចហ្នឹង ។

ឡុង ដានី:	ខែប្រូតឆ្នាំ៧៧ហ្នឹង យ៉ាងម៉េចបានព្រះអង្គទៅកន្លែងភ្នំទ្រយោងហ្នឹង?

អឿយ ពឿ:	ដូចអាត្មានិយាយខាងដើមអីចឹង មានគ្នាអាត្មាមួយណា វាឈ្មោះ អាទូច ។

ឡុង ដានី:	ឈ្មោះ ទូច?

អឿយ ពឿ:	ឈ្មោះ ទូច ។ វា ឲ្យវាធ្វើនេសាទ ឲ្យវាដើរបង់សម្រាប់យកត្រីយកអីមកឲ្យគេស៊ីណា ក្នុង៣០នាក់ហ្នឹងណា ។

ឡុង ដានី:	ករុណា!

អឿយ ពឿ:	ហើយនិយាយទៅ កាលសម័យហ្នឹង គេហៅនេសាទ ។

ឡុង ដានី:	អ្នកនេសាទ?

អឿយ ពឿ:	អ្នកនេសាទ ។ ហើយទៅ ឃើញអំពៅគេឃ្លាន ។

ឡុង ដានី:	ឃើញអីគេ?

សុខ វណ្ណះ:	អំពៅ!

អឿយ ពឿ:	អំពៅ ។

ឡុង ដានី:	ករុណា!

អឿយ ពឿ:	ហ្នឹងហើយ! ឃើញអំពៅគេដាំ ។ គេដាំ វាឃ្លានវា ទៅកាច់អំពៅគេ ។ កាច់អំពៅ មិនទាន់បានស៊ីផង គេឃើញគេបាញ់ ។ បាញ់ វារត់គេច ។ រត់គេចៗ ។ ប៉ះអាត្មា ។ ប៉ះអាត្មា អាត្មាហូបបាយរួច ថ្ងៃនោះគេឲ្យសម្រាក ។ គេឲ្យសម្រាកអាត្មាយកមុង បានទៅរូសត្រីតាមទឹកព្រៃវារត់យំ ។ គ្នា៣នាក់ ង៉ូងៗ ហ៎! អាពីរនាក់សម្លេងនេះ សម្លេងអាទូច ។ អាទូចកើតអីទេដឹង? ថាអញ្ចឹង ។ ចេញមកឃើញអាកូនឈ្លបនោះ ដេញបាញ់គ្រាប់ថ្មហ្នឹង បែកអស់ ពោះបែកអស់ ។

ឡុង ដានី:	យកចម្ពាមដេញបាញ់?

អឿយ ពឿ:	ចម្ពាមដេញបាញ់ ។ ឯងមិនឈប់នោះ ។

ឡុង ដានី:	កូនឈ្លប?

អឿយ ពឿ:	ពួកកូនឈ្លបតូចៗ ។ កុមារតូចៗ ។

ឡុង ដានី:	កុមារតូចៗហ្នឹង ពួកណា?

អឿយ ពឿៈ ពួកអ្នកចាំចំការនោះអី ។ ពួកឈ្លបនៅចំការ ។

ឡុង ដានីៈ ចំការនៅណា?

អឿយ ពឿៈ នៅហ្នឹង គេហៅ ភ្នំលាប ។

ឡុង ដានីៈ នៅភ្នំលាប?

អឿយ ពឿៈ ភ្នំ លាប ចំការនៅស្អឹង ។

ឡុង ដានីៈ កណា!

អឿយ ពឿៈ នៅស្អឹងភ្នំលាបចំការនោះ ។ ទេវតាជួយអាត្មានោះទៀត កុំអីអាត្មាយ៉ាប់ណា ។ កុំអីអាត្មាយ៉ាប់ទៀត អាត្មាទៅធានាវាទៀត ។ អាត្មាហៅឲ្យឈប់ វាក៏ឈប់ ។ ឈប់សុំថាប្អូនអើយបងសុំផង ។ គ្នាបានជាខុសក៏អធ្យាស្រ័យឲ្យគ្នាផង ។ ថាទេ! អធ្យាស្រ័យខ្ញុំអត់ហ៊ានអធ្យាទេ ។ ទៅជួបមេ ទៅជួបអ៊ុំខ្ញុំសិន ។ ឲ្យហៅទៅជួបអ៊ុំ ។

ឡុង ដានីៈ អ៊ុំណា?

អឿយ ពឿៈ គាត់ប្រធានចាំចំការនោះ ។ ហើយសំណាងល្អទៀត ប៉ះឪពុកធំម ប៉ះឪពុកធំមអាត្មាទៀត ។

ឡុង ដានីៈ អ្នកប្រធានចាំចំការឪពុកធម៌?

អឿយ ពឿៈ ហ្នឹងហើយ! ប៉ះឪពុកធំមអាត្មា តែអាត្មាក៏មិនដែលស្គាល់គាត់ គាត់ក៏មិនដែលស្គាល់អាត្មា ។ ដល់ទៅដល់គាត់សួរថា មិត្តឯងហើយដែលមកលួចកាច់អំពៅ ។ ថាទេអ៊ុំ ខ្ញុំមិនបានកាច់អំពៅទេ ។ អាមួយនេះទេ តែខ្ញុំ ខ្ញុំមិនបានកាច់ទេ ។ ប៉ុន្តែគ្នាខ្ញុំនេះឯង ក៏ខ្ញុំមកសុំទោស សុំទាន សុំមាន អ៊ុំឯង ឲ្យអ៊ុំឯងអធ្យាស្រ័យឲ្យផងទៅអ៊ុំ ។ គាត់សួរថា អានាងឯងនៅណា? ថាខ្ញុំនៅឈូក ។ ឯងស្គាល់អាឈូកដែរអត់? ឈូកហ្នឹងឪពុកធំ គាត់បងញ៉ោមប្រុសអាត្មា ។ ថាស្គាល់ គាត់អ៊ុំខ្ញុំតើស ។ អ៊ូ អាំ! ប៉ះកូនឯងបណ្ដោយ ។ គាត់ថាអញ៉ោះ អញនេះក្អើអាឈូក ។ ណែ៎ កូនឯងសំណាងល្អហើយកូនឯងមកប៉ះឪ ។ ណែ៎! បើក្រៅពីឪណា គេឲ្យដាំអំពៅ៥០អន្លង់ គេឲ្យរែកទឹកស្រោច៥០អម្រែក ។ ហើយទឹករែកឯណា មើលពីលើ មើលពីច្រាំងមក យី! ចោតសន្ទឹមអញ៉ោះ ក៏រែកម៉េចបាន មិនដាប់ហើយអានោះ ស្អឹងនោះជ្រៅណាស់ ។ ស្អឹងនៅប្រលោះកណ្ដាលព្រៃមាន់ ប្រលោះកណ្ដាលភ្នំលាបនោះ ជ្រៅណាស់ស្អឹងនោះជ្រៅណាស់ ខែប្រាំងមើលទៅសន្ទឹម ។ អាត្មាថា អ៊ូ! ស្រេចបាត់ហើយ ងាប់បាត់ហើយអាទូច ។ គាត់ក៏ឲ្យអំពៅមួយបាច់មកទៀត ។ សំណាងណាស់ កុំអីយ៉ាប់នោះឯងគេឲ្យរែកទឹកងាប់ហ្នឹង ។ ឯងមិនបាននេះ តែឯងទៅធានាវា គេថាតែឯងចូលដៃ

ចូលដើរជាមួយគ្នាហ្នឹងឯង ៗ មកដល់ប្រាប់វាថាអាទូច ពេលទៅដល់ បើគេសួរថាឃុំទិចណា ៗ វាហើមនោះ ៗ

ឡុង ដានី: ករុណា!

អឿយ ពឿ: វាហើមឡើងនេះអស់ ៗ អាគ្នាមកដល់ ដល់គេហូបបាយ គេហូបបាយទាំងអស់គ្នា ៗ ហូបបបរ គេចែករបប ៗ ស៊ីៗទៅ អាមួយនោះវាចង់ស៊ើច ៗ មកពីអានៀមវាចង់ស៊ើច វាឃើញមុខអាទូចដែលវាហើម វាចង់ស៊ើច ៗ វាស៊ើច វាធ្វើខឹកៗៗៗ ៗ មេកងគេលឺ មិត្តឯងស៊ើចអី ៗ អាទូចវាឆ្លើយ វាខឹងវាឆ្លើយ ស៊ើចខ្ញុំ ៗ កើតអ្វីមិត្តឯងកើតអ្វី? អាគ្នាថា ឃុំទិចវា ៗ មិនមែនឃុំទេ ៗ វារកបានរាប់ណា ៗ មិនមែនឃុំទេ គេបាញ់ ៗ ម៉េចបានគេបាញ់? ខ្ញុំទៅកាច់អំពៅមិនទាន់បានហូបផង គេបាញ់ខ្ញុំ ៗ វាឆ្លើយអីចឹង ស្មានតែរួចខ្លួនរបស់វាទេដឹង ៗ ចុះម៉េចបានមកបាន? មិត្តពឿ ទៅសុំគេ ត្រូវជាឪពុកធម៌ មិត្តពឿ ឲ្យទាំងអំពៅមកទៀត ៗ គេថាមិត្តឯង តិះទៀនតែវាមិនទិតៀន ទិតៀនទាំងអាគ្នាទៀត ម៉ោង ១២.០០ យប់បាន បានដេក ៗ

ឡុង ដានី: ករុណា!

អឿយ ពឿ: ថ្ងៃអស់កម្លាំងហើយ យប់មិនបានដេកទៀត ៗ វាថាឯងណាបេះដឹង ៗ ឯងស្អីបានឯងបេះដឹង ឯងមេកង ហើយឯងមេក្រុម បានឯងបេះដឹងទៅធានាទៅរាប់នេះ ៗ គេមិនដែលឲ្យយើងត្រូវ យើងថាយើងត្រូវទៅណា ៗ

ឡុង ដានី: ករុណា!

អឿយ ពឿ: យើងធ្វើដូចថាយើងធ្វើជួយគ្នាឯង ៗ បើគេ គេមិនថាអញ្ចឹងណា គេថាឯងមានអំណាចអ្វី ឯងមានរដ្ឋអំណាចអ្វី ៗ ឯងមេកង ឯងមេក្រុមណា ៗ តាមការពិតឯងមានធ្វើអី តែគ្នាឯង ៗ

ឡុង ដានី: កុរណា! ហើយទៅម៉េចទៅ?

អឿយ ពឿ: ហើយទៅ ម៉ោង១២យប់ បានគេឲ្យមកដេក ៗ រួចខ្លួនទាំងអស់គ្នាទៅ ៗ អាគ្នាបេះតែទទួលកំហុសទៅៗ ៗ មិនខុសក៏ទទួលកំហុសដោយរីករាយ ៗ ខ្ញុំដាក់កែប្រែតាមសមមិត្ត ប៉ុណ្ណឹងរួចខ្លួនហើយ បើថាទៅទីងរាប់ រាប់នេះហើយ នៅសម័យនោះ ៗ បានថា សម័យនោះ .........

ឡុង ដានី: ហើយម៉េចបាន ហើយបានគេឲ្យទៅមើលនៅភ្នំលាប ទៅមើលអ្នកទោស ឬក៏ ?

អឿយ ពឿៈ ហ្នឹងហើយ! ក្រោយ បានក្រោយ បានគាត់ មេកងនោះ មេកងនោះគាត់ឈ្មោះបង សឺន ។ បង សឺន មិនដឹងអ្នកនៅខាងណាទេ ។ អាត្មាមិនដឹងគាត់ទេឈ្មោះ សឺន ។

ឡុង ដានីៈ មិនមែនពួកនិរតីទេ?

អឿយ ពឿៈ ទេ! ប្រជាជនដូចគ្នាយើងអញ្ចុះឯង ។ ប៉ុន្តែគាត់មិនសូវធ្វើបាបអ្វីទេ គាត់គ្រាន់តែថា គាត់គ្រាន់តែណែនាំ ណែនាំហើយ ។ បើនិយាយពីតិះទៀនច្បាស់ហើយគាត់នោះ ប៉ុន្តែគាត់មិនដែលថាឲ្យនេះទេ ។ គាត់តិះទៀន គាត់និយាយពន្យល់ យូរណាស់និយាយ និយាយឡើងឯងខ្ជិល ។ ប៉ុន្តែមិនដឹងធ្វើយ៉ាងម៉េច ។ ហើយដល់ពេលនេះទៅ គាត់ថា គាត់និយាយជាមួយអាត្មា និយាយតែអានោះ ។ គាត់ស្រលាញ់អាត្មា គាត់ឃើញ អាត្មាធ្វើការ មិនដែលឈប់មិនដែលឈរ ។ គាត់ថា ថ្ងៃនេះអញនាំឯងទៅមើល ។ អញនាំឯងទៅមើលគុកនៅភ្នំទ្រយោង ។ ទៅចូលម៉េចបានលោកបង? ហៅតែលោក បងទេ ។ ពិបាកចូលអី ដែលពិបាកធ្វើគុកអីអ្ហា ។ តែទៅឃើញហើយ ។ តែទៅឃើញ វានៅវាលមុខដួល ដែលឯងកម្ចាំងខ្សោយផង ដល់ទៅឃើញអញ្ចឹង វាទៅកើតវិល មុខណា ។

ឡុង ដានីៈ វិលមុខ?

អឿយ ពឿៈ វាវិលមុខខ្លួនឯង វាហ្នឹងកើតដួលខ្លួនឯង ព្រោះវាដំបៅរយ៉េករយើក បែកដែលថ្មវា ខ្ទាតមក ។

ឡុង ដានីៈ ព្រះអង្គ ទៅមើលគេឃើញគេ ដូចថា ឃើញគេ ព្រះអង្គចង់វិលមុខ?

អឿយ ពឿៈ ចង់តក់ស្លុតខ្លួនឯង ស្លុតខ្លួនឯង ។

ឡុង ដានីៈ ឃើញទិដ្ឋភាពហ្នឹងយ៉ាងម៉េចខ្លះបានជាព្រះអង្គ...?

អឿយ ពឿៈ អ៊ូ! ស្លុតចិត្តណាស់ ដូចថាវេទនាណាស់ ព្រោះវាបែក ហើយឃើញទាំងច្រវាក់ជាប់ ទាំងជើងទៀត ។ ហើយឃើញមនុស្សស្លៀកខោស ។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ អាត្មាថា តោះ! ឆាប់ទៅវិញទៅលោកបង ។ ឆាប់ទៅវិញទៅ ។

ឡុង ដានីៈ កាលហ្នឹង ពេលដែលមេកង ឈ្មោះ សឺន ហ្នឹង ជូនព្រះអង្គទៅ ទៅតែព្រះអង្គម្នាក់ ឬក៏...?

អឿយ ពឿៈ ទៅតែម្នាក់ឯង ។

ឡុង ដានីៈ តែម្នាក់ទេ?

អឿយ ពឿៈ តែម្នាក់ឯង ។ ២នាក់គាត់នោះឯង ។

ឡុង ដានី៖ ចុះគាត់ចូលទៅ គាត់អត់នេះទេ អត់មានសុំគេអីទេ ចូលទៅទេ?

អឿយ ពឿ៖ សុំគេ ប៉ុន្តែស្រុកគេនោះឯង គេស្គាល់គ្នាទៅ ។

ឡុង ដានី៖ សុំពីណាគេហ្នឹង?

អឿយ ពឿ៖ សុំមេគេនោះ ។

ឡុង ដានី៖ មេឈ្មោះអ្វីហ្នឹង?

អឿយ ពឿ៖ មិនដឹងទេ! អាត្មាមិនដឹងទេ ។ អាត្មាមិនដឹង ។

ឡុង ដានី៖ ដល់ពេលព្រះអង្គចូលទៅដល់ក្នុំទ្រយោងទៅ ឃើញអ្នកទោសជាប់ខ្នោះជើង?

អឿយ ពឿ៖ ហ្នឹងហើយ!

ឡុង ដានី៖ បែកជើង បែកដៃ?

អឿយ ពឿ៖ បែក ។

ឡុង ដានី៖ ជន្លុង បែកក្បាលអីទៀត?

អឿយ ពឿ៖ ហ្នឹងហើយ! បែក ។ ថ្មនោះ ។

ឡុង ដានី៖ កំពុងតែវៃថ្ម?

អឿយ ពឿ៖ កំពុងតែវៃថ្ម ។ ថ្មនេះ ថ្មវាដែលអ្នកឯងមិនចេះវៃណា អ្នកឯងមិនចេះទៅ ថ្មវាខ្ទាត មកនោះ ។

ឡុង ដានី៖ ករុណា!

អឿយ ពឿ៖ វាគ្មាននរណាវៃទេ ថ្មហ្នឹងវាខ្ទាតមកត្រូវ ។

ឡុង ដានី៖ ច្រើនទេព្រះអង្គអ្នកដែលជាប់?

អឿយ ពឿ៖ ច្រើន ។

ឡុង ដានី៖ ប្រហែលប៉ុន្មានដែរ ដែលព្រះអង្គឃើញ?

អឿយ ពឿ៖ ថ្ងៃហ្នឹង ប្រហែល ៨-១០-២០នាក់ ។

ឡុង ដានី៖ ៨-១០-២០នាក់!

អឿយ ពឿ៖ អើម!

ឡុង ដានី៖ កំពុងតែវៃថ្ម ហើយ ....?

អឿយ ពឿ៖ កំពុងតែវៃថ្ម ។

ឡុង ដានី៖ ឃើញស្ថានភាពអ្នកទោសហ្នឹងយ៉ាងម៉េចទៅ?

អឿយ ពឿ៖ អ៊ូ! យ៉ាប់ណាស់ ។

ឡុង ដានី៖ យ៉ាប់!

អឿយ ពឿ៖ វេទនាណាស់ ។

ឡុង ដានី៖ ដើរជាប់ច្រវាក់?

អឿយ ពឿ៖ ដើរជាប់ច្រវាក់ ។ ហើយសួរគាត់ទៀត សួរគាត់ថា ដែលវ៉ៃគេ គេឲ្យវៃប៉ុន្មានលោកបង? ២.៥ ម៉ែត្រ ។ ២.៥ ម៉ែត្រគីប ។ ថា ២គីបកន្ទះ គាត់ថាអញ្ចេះ បើមិនរួចគេមិនឲ្យបាយទេ ។ គេមិនឲ្យមួយរបបទេណា ។ បបរ៣វែក បើវាយគេមិនរួចគេមិនឲ្យស៊ីទេណា គេឲ្យឯងអត់ណា ។

ឡុង ដានី៖ កាលហ្នឹង គេហៅគុកភ្នំទ្រយោងអញ្ចឹង?

អឿយ ពឿ៖ ថាគុកភ្នំទ្រយោង ។

ឡុង ដានី៖ ពីណាអ្នកថាគុកភ្នំទ្រយោង?

អឿយ ពឿ៖ លោកបងនោះហើយ លោកបងសឺន គាត់ថាអញមកមើលគុកភ្នំទ្រយោង ។

ឡុង ដានី៖ អើម!

អឿយ ពឿ៖ គុកភ្នំទ្រយោងអីនៅកណ្ដាលវាលអញ្ចេះ ថាអញ្ចឹង ។

ឡុង ដានី៖ អញ្ចឹង!

អឿយ ពឿ៖ ក្រោយៗមកបាននឹកឃើញ អូ! នេះគុកអត់ជញ្ជាំង ។ នេះឯងគុកអត់ជញ្ជាំង ។

ឡុង ដានី៖ គុកភ្នំទ្រយោងហ្នឹងធំទេ កាលហ្នឹងគុកហ្នឹង?

អឿយ ពឿ៖ អាត្មាមិនពិចារណាទេ ។ ដូចអាត្មាជិវាបអញ្ចឹងឯង អាត្មាមិនបានទៅតែឃើញ ទៅតែឃើញទិដ្ឋភាពនោះ ដូចថាវាឆ្អែតអស់មិនចង់មើលអីទេ ។ សូម្បីតែពុទ្ធបរិស័ទគេនាំទៅមើលកន្លែងគុកទួលស្លែងនេះ អាត្មាមិនទៅទេ ។

ឡុង ដានី៖ ករុណា!

អឿយ ពឿ៖ គេសួរថា គេសួរអាត្មា ថាម៉េចបានគេជគុណមិនចង់ទៅ? ទៅក៏វាមិនបានផលអ្វីសម្រាប់អាត្មា ។ អត់បានផលអ្វីទេ ។

ឡុង ដានី៖ ហើយព្រះអង្គទៅមើលហ្នឹងយូរទេ នៅគុកភ្នំទ្រយោងហ្នឹង?

អឿយ ពឿ៖ យូរហើយ ។ ទៅមើលមួយភ្លែតតែប៉ុណ្ណោះឯងក៏មកវិញឆ្នាំ៧៧នោះឯង ។ ដល់មកវិញក៏វាកើត មកវិញបានប្រហែលជាកន្លះខែ វាកើតយើងរំដោះបានណា ។

ឡុង ដានី៖ អើម!

អឿយ ពឿ៖ កាលស្រុកយើងឯករាជណា ។

ឡុង ដានី៖ ករុណា!ហើយព្រះអង្គពេលដែលទៅមើលគុកភ្នំទ្រយោង ព្រះអង្គដឹងថាពីណាគេមេគុកនៅភ្នំទ្រយោងហ្នឹង?

អឿយ ពឿ៖ ទេ! អាត្មាមិនដឹងទេ។ ប៉ុន្តែថាកន្លែងនោះ អាត្មាគ្រាន់តែដឹងថា យាយឥតែមៗៗ។ គ្រាន់តែថា គុកយាយថែមៗៗ ប៉ុណ្ណោះឯង។

ឡុង ដានី៖ គុក យាយថែម?

អឿយ ពឿ៖ ហ្នឹងហើយ។

ឡុង ដានី៖ អើម!

អឿយ ពឿ៖ អានេះមិនមែនដឹង! ដឹងតែពីគ្នាឯង ដូចថាមាត់សេកមាត់សត្វណា។ ចុះខ្លាចទាំងអស់គ្នា ប្រយ័ត្នវើយ ប្រយ័ត្នគុកយាយថែមវើយ។

ឡុង ដានី៖ អ៊ូ!

អឿយ ពឿ៖ ប្រយ័ត្នវើយ ប្រយ័ត្នគុកយាយថែមវើយ។

ឡុង ដានី៖ អ្នកដែលធ្វើការជាមួយគ្នាហ្នឹង គេថា ប្រយ័ត្នគុកយាយថែម?

អឿយ ពឿ៖ ប្រយ័ត្នវើយ ប្រយ័ត្នគុកយាយថែមវើយៗ។ យើងប្រយ័ត្នវើយ។

ឡុង ដានី៖ យាយថែម នៅណាកាលហ្នឹង?

អឿយ ពឿ៖ នៅភ្នំលាបនោះអី។

ឡុង ដានី៖ គាត់នៅភ្នំលាបហ្អេ៎?

អឿយ ពឿ៖ នៅភ្នំលាបហ្នឹង។

ឡុង ដានី៖ គាត់ធ្វើអីគេកាលហ្នឹង?

អឿយ ពឿ៖ ចៅហ្វាយស្រុកព្រះនេត្រព្រះ។

ឡុង ដានី៖ ចៅហ្វាយស្រុកព្រះនេត្រព្រះ?

អឿយ ពឿ៖ ហ្នឹង!

ឡុង ដានី៖ ព្រះអង្គ ធ្លាប់ឃើញមុខយាយថែម ទេ?

អឿយ ពឿ៖ ឃើញតើ! ឃើញគាត់ជិះម៉ូតូ។ ចុះនៅថ្នល់អញ្ចេះនោះ។

ឡុង ដានី៖ អ៊ូ! គាត់ជិះម៉ូតូ?

អឿយ ពឿ៖ ជិះម៉ូតូ គេឌុបម៉ូតូ។ មានម៉ូតូសេអិលមួយ ឌុបគាត់ទៅមកៗ។

ឡុង ដានី៖ ម៉ូតូពណ៌អ្វី?

អឿយ ពឿ៖ ម៉ូតូសេអិលពណ៌ខៀវ។

ឡុង ដានី៖ ពណ៌ខៀវ?

អឿយ ពឿ៖ ម៉ូតូសេអិលគាត់មួយ។ ឌុបគាត់ទៅមកៗ។

ឡុង ដានី៖ ពីណាឌុប?

អឿយ ពឿៈ មិនដឹងថាពីណាទេ កាលហ្នឹង ។ មិនទាន់ស្គាល់ មិនស្គាល់ច្បាស់ថានរណា ។

ឡុង ដានីៈ ប៉ុន្តែគាត់មិនមែនជិះខ្នងឯងទេ?

អឿយ ពឿៈ ទេ! គេឌុប ។ ថានេះ និរសារយាយថែម ថានិរសារ ។

ឡុង ដានីៈ ឈ្មោះអីគេ?

អឿយ ពឿៈ ទេ! មិនស្គាល់ទេ ។ មិនស្គាល់ទេ ។

ឡុង ដានីៈ អត់ស្គាល់ឈ្មោះ ។ ប៉ុន្តែឃើញគេឌុបគាត់ច្បាស់ដែរ?

អឿយ ពឿៈ ឃើញច្បាស់ ។ មកយាយថែមមកហើយ ។

ឡុង ដានីៈ រាងម៉េច យាយថែម រាងគាត់?

អឿយ ពឿៈ កាលពីក្មេង គាត់ស៊ីម្ជូ គាត់ជូតក្បាល បបូរមាត់គាត់ស្រួចអីចេះ ។

ឡុង ដានីៈ គាត់មាឌធំឬតូច?

អឿយ ពឿៈ ធំណាស់ ។ យាយ ថែមមាឌធំ ។ អាត្មាមិនមានឃើញផ្ទាល់ទេ ឃើញតែនៅលើម៉ូតូ ។

ឡុង ដានីៈ កុរណា! អត់ដែលបាននិយាយជាមួយយាយថែម?

អឿយ ពឿៈ ទេ! ដែលហ៊ានបាននិយាយ ។ សម័យនោះដូចអាត្មាប្រាប់ហើយឲ្យតែអ្នកធំ ឲ្យតែ យើងមានប្រវត្តិដូចអាត្មាអញ្ចឹង ប្រវត្តិឱរត់ទៅថៃអីហ្នឹង មិនហ៊ាននៅមើលមុខគេទេ ។

ឡុង ដានីៈ អញ្ចឹង អ្នកធ្វើការជាមួយគ្នាដឹងថា អ៊ូ! ប្រយ័ត្នជាប់គុកយាយថែម?

អឿយ ពឿៈ ប្រយ័ត្នជាប់គុកយាយថែមវើយ ។

ឡុង ដានីៈ ដឹងថាគុកយាយថែមហ្នឹង មានមនុស្សស្លាប់ច្រើនទេ ឬអត់ទេ?

អឿយ ពឿៈ គេថាសម្លាប់ច្រើន បានគេភ័យគុកយាយថែមៗនោះ ។ គេថាប្រយ័ត្នណាស់ណាគុក យាយថែមៗ ។

ឡុង ដានីៈ អើម!

អឿយ ពឿៈ គេថាអញ្ចេះ ប៉ុន្តែឯងមិនដែលឃើញទេ ប៉ុន្តែថាលឺតែគ្នាឯងទេថា ប្រយ័ត្នគុកយាយ ថែមវើយ ។

ឡុង ដានីៈ អើម!

អឿយ ពឿៈ ប្រយ័ត្នជាប់គុកយាយថែមវើយ ។

ឡុង ដានីៈ មានពីណាគេធ្លាប់បានជាប់គុកយាយថែមមកដែរទេ?

អឿយ ពឿៈ ទេ! គ្នាអាត្មាគ្មានទេ ។

ឡុង ដានីៈ អត់មានទេ?

អឿយ ពឿៈ អត់ទេ! មានតែខាងគេខាងនោះ ។

ឡុង ដានីៈ ខាងណា?

អឿយ ពឿៈ មានតែខាងចល័ត ខាងមកពីទីក្រុងភ្នំពេញនេះឯង មើលទៅណាព្រោះគ្នាអត់ចេះវ៉ៃថ្មសោះ ។ គ្នាមិនចេះវ៉ៃថ្មអី ។ ធម្មតាញញួរដងវែងណា ដងវែងទៅវ៉ៃដែលថ្មស្រួលអី ។ ហើយបើយើងនៅតាមជនបទអញ្ចឹង យើងច្នៃប្រឌិតរកដងទន់ៗមកវ៉ៃទៅផុកៗ ៗ ៗ ទៅ ។ ហើយមនុស្សធ្លាប់ស្រណុកណា ទៅវ៉ៃយកតែប្រាស់អាយុ មានអីដាំងៗ ៗ ៗ ទៅបែកខ្ទាតត្រូវតែខ្លួនឯង ម៉ាកម្លាំងវ៉ៃហ្នឹង ៥០គីឡូ ៦០គីឡូអីខ្ទាតមកត្រូវ ។

ឡុង ដានីៈ ព្រះអង្គធ្លាប់ទៅឃើញតែម្តងហ្នឹងទេ?

អឿយ ពឿៈ ម្តងមួយភ្លែតប៉ុណ្ណោះឯង មិនបានយូរផង ។ មកវិញភ្លាម ។

សុខ វណ្ណៈ អត់បានដើរជុំវិញអីទេ?

អឿយ ពឿៈ អត់ទេ! ទៅតែឃើញអញ្ចឹង ឈរមួយសន្ទុះ តេះល្បេងទៅវិញ ។

ឡុង ដានីៈ ប៉ុន្តែ ឃើញគេដាក់ខ្នោះដើង?

អឿយ ពឿៈ ឃើញ ឃើញគេដាក់ ព្រោះអាត្មានៅអញ្ចឹងឯង ហើយដល់នេះអាត្មាពិនិត្យមើលអាត្មាអ្នកពិនិត្យអីចុះឯង ឃើញជាប់ខ្នោះ ច្បាស់ថាជាប់ខ្នោះ ។

ឡុង ដានីៈ ហើយជើងបែកអស់?

អឿយ ពឿៈ ដៃជើងបែកអស់លីង ។ ហើយប៉ងតាំងពីក្បាល រុំតាំងពីក្បាលទៅអី ។ អាត្មាទៅឃើញមួយភ្លែតនោះឯង ។

ឡុង ដានីៈ អើម!

អឿយ ពឿៈ អាត្មាទៅហើយ មិនហ៊ាននៅទេ ។

ឡុង ដានីៈ ហើយ ព្រះអង្គមានដែលលឺឈ្មោះ តាសឿន តាឈឿន អីអ្នកគ្រប់គ្រងនៅគុកហ្នឹងដែរអត់ទេ?

អឿយ ពឿៈ ទេ! គ្រាន់តែអាត្មាស្គាល់តែ តាឈឿន តាសឿនក្តាប់ពួកអាត្មានេះឯង ។

ឡុង ដានីៈ តាឈឿន?

អឿយ ពឿៈ ឈ្មោះ តាឈឿន មេធំ ។

ឡុង ដានីៈ តាសឿន?

អឿយ ពឿៈ តាសឿន បន្ទាប់ ។ ២នាក់ហ្នឹងក្តាប់ជាមួយគ្នាទេ ប៉ុន្តែមួយកន្លែងខាងលិច មួយកន្លែងខាងកើត ។ ប៉ុន្តែ អាត្មាសង្ស័យគ្នាគេនោះឯង ក៏មិនដឹង ។

ឡុង ដានីៈ ឈឿន ហើយ សឿនហ្នឹង ក្តាប់នៅណា?

អឿយ ពឿៈ ក្តាប់ពួកអាត្មានេះឯង ៗ ឈឿននៅស្ពាន១ អ៊ូ! តាសឿន ៗ តាសឿននោះទាប ខ្មៅ ៗ

ឡុង ដានីៈ ទាបខ្មៅ!

អឿយ ពឿៈ តាឈឿន នោះខ្ពស់ធំ ៗ

ឡុង ដានីៈ ចុះមានតាមួយគាត់វាងដុះពុកមាត់វាងស្រម៉ោមបន្តិច មានដែលឃើញទេព្រះអង្គ?

អឿយ ពឿៈ តាទុយ ទេ ៗ មានតាទុយ មួយទៀត ៗ ឈ្មោះ តាទុយ មួយទៀត ៗ នៅជាមួយ តាសឿន ឈ្មោះ គាត់ តាទុយ ៗ

ឡុង ដានីៈ អើម!

អឿយ ពឿៈ ឈ្មោះ តាទុយ ៗ តាទុយហ្នឹង ទាប ប៉ុន្តែ មុខស្រួច ៗ

ឡុង ដានីៈ មុខស្រួច!

អឿយ ពឿៈ គាត់វាងទាប ៗ

ឡុង ដានីៈ កណា! អញ្ចឹង ព្រះអង្គឃើញគុកភ្នំទ្រយោង ហ្នឹងតែមួយភ្លែតទេ?

អឿយ ពឿៈ តែមួយភ្លេទទេ ៗ

ឡុង ដានីៈ ហើយកាលពីជំនាន់ ព្រះអង្គនៅខាងព្រៃមាន់អី ព្រះអង្គធ្លាប់ជួបតាខូទេ?

អឿយ ពឿៈ ទេ! មិនដែលបានជួបគ្នាទេ ៗ

ឡុង ដានីៈ អត់ដែលបានជួបទេ?

អឿយ ពឿៈ អត់ដែលបានជួបទេ ៗ

ឡុង ដានីៈ ស្គាល់ តាខូ តាំងពីអង្កាលមក?

អឿយ ពឿៈ ស្គាល់យូរហើយ! ប៉ុនស្គាល់ដូចដឹងអីចឹងណា គេថានេះតាខូ ៗ តាខូ ខាងសេដ្ឋកិច្ច ៗ ឯងក៏ស្គាល់មើល ៗ ទៅណា ព្រោះ តាខូ នៅខាងពាយ័ព្យ ៗ គាត់នៅសម័យតស៊ូ គាត់នៅខាងសេដ្ឋកិច្ចដឹកជញ្ជូនណា ៗ

ឡុង ដានីៈ កុរណា!

អឿយ ពឿៈ គាត់ដឹកជញ្ជូនដូចថា អង្ករឡូទ័ព ដឹកឲ្យទៅ គេក៏ស្គាល់គាត់ច្រើន មនុស្សតាខូណា ប៉ុន្តែ មនុស្សគាត់ថាមនុស្សមិនវៃ គាត់មិនវៃទេ តាខូ ៗ មនុស្សគាត់ត្រង់ ត្រង់ហើយ មនុស្សតែត្រង់ហើយ ល្ងង់ហើយ ត្រង់ហើយ កាចណាស់ ៗ អត់ចេះយល់ញាតិទេ ៗ ប៉ុន្តែ គាត់ថាមិនមែននាទីគាត់ទេ នាទីសម្ងាប់អី មិនមែននាទីគាត់ទេ ៗ គាត់ដោយ

សាររូបថ្លូននេះ អាត្មាដឹងថា តាខូ រូបថ្លូននេះ ដោយសារ តាខូ មានបុណ្យខ្លះទេ កុំអីបែបទៅកកោះបាត់ហើយ ពីព្រោះគេទៅច្រើនដែរ៉ ម៉ាសេរីគាត់ទៅច្រើនណាស់ ។

ឡុង ដានី៖ ករុណា!

អឿយ ពឿ៖ នៅគាត់មួយនេះឯង នៅរូបថ្លូន ។

ឡុង ដានី៖ ប៉ុន្តែ កាលព្រះអង្គនៅជំនាន់ពាឆ្នាំហ្នឹង ដែលស្គាល់ តាខូ ដែលឃើញ តាខូ ដែរ អត់?

អឿយ ពឿ៖ ទេ មិនដែលបានជួបមុខ តាខូ ទេ ។

ឡុង ដានី៖ អើម!

អឿយ ពឿ៖ គ្រាន់តែឃើញជិះម៉ូតូជិះអី បានសួរទៅគេថា នេះខូ ។

ឡុង ដានី៖ កាលហ្នឹង គាត់ធ្វើអី?

អឿយ ពឿ៖ គាត់អត់មានភារះកិច្ចអីទេ ព្រោះគេដកអស់ហើយ ពាយ័ព្យណា ។

ឡុង ដានី៖ ពាយ័ព្យ?

អឿយ ពឿ៖ ពាយ័ព្យ គេដកអស់ហើយ ។ មានអីទេ ។

ឡុង ដានី៖ ប៉ុន្តែ ដកអស់ហើយ ម៉េចបានគាត់មានម៉ូតូជិះ?

អឿយ ពឿ៖ ព្រោះគេសម្រាប់ប្រើគាត់នោះ ។

ឡុង ដានី៖ គេប្រើគាត់ធ្វើអីគេ?

អឿយ ពឿ៖ គេប្រើគាត់ឲ្យដូចថា ភាសាគេថាម៉េច ពីដើមគេថារត់បុត្រណា ។

ឡុង ដានី៖ កុរណា!

អឿយ ពឿ៖ ដល់សម័យនោះ គេថាហៅ និរសារ ។ រត់ទៅប្រាប់ទីនេះ រត់ទៅប្រាប់ទីនោះ រត់ទៅប្រាប់នោះ ព្រោះវាមាន ឧទាហរណ៍ថា និរតីមកមុនដំបូង វាអត់ទាន់ស្គាល់គេណា វាអត់ទាន់ស្គាល់ប្រធានសហករណ៍នេះ ឈ្មោះនេះ ប្រធានក្រុមនោះឈ្មោះនោះ ម្លោះ ហើយមាននរណាមួយវាងជំនិត មានពាយ័ព្យណាមួយវាងជំនិតអញ្ចឹងយក ពាយ័ព្យនោះគ្រាន់ធ្វើការជំនួសពីមុខ ។

ឡុង ដានី៖ អូ៎! អញ្ចឹងបានន័យថា គេទុក តាខូ មួយ ទុកគ្រាន់ប្រើការ?

អឿយ ពឿ៖ ហ្នឹងហើយ! គ្រាន់ប្រើការទេ ។

ឡុង ដានី៖ ប្រើការ ឧបមាថា គេចង់ស្គាល់ឃុំនេះ ឃុំនោះ គេឲ្យគាត់ជូនទៅ ។

អឿយ ពឿ៖ ជូនទៅ ។ ឲ្យតាខូ នេះឯងជូនទៅ ។

ឡុង ដានី៖ ហើយបើសិនជាគេត្រូវការចាប់ពីណាពីណី ក៏គេឲ្យ តាខូ ជូនទៅ?

អឿយ ពឿៈ ហ្នឹងហើយ! តាខូ ហ្នឹងឯង ព្រោះតាខូ អ្នកស្គាល់នោះ។ តាខូ អ្នកស្គាល់ហ្នឹងឯង។ អញ្ចឹង បានថា តាខូ លួង។ គាត់លួង គាត់ចង់បាន មនុស្សលួងចង់ធំ ហើយមិនគេចចេញពីកន្លែងគេដែលយើងថា យើងទៅគេច ចេញទៅនៅស្រុកទៅនៅស្រែអី។ គេមិនមែនលួងគេរួចខ្លួនមែន ប៉ុន្តែគេគេចចេញទៅនៅស្រុកគេវិញ។ នៅសហករណ៍គេវិញ តែតាខូ គាត់អត់បានទៅណាទេ។ គាត់នៅនោះហើយ ប៉ុន្តែស្រុកគាត់ជិតនោះដែរនោះ។ ស្រុកគាត់ជិតនោះឯង ប៉ុន្តែបានថា មនុស្ស តាខូ មនុស្សលួង។ ប្រសិនបើកុំលួង កុំទៅរកអែបគេ មិនបាននរណាស្គាល់គាត់ច្រើនទេ។ ប៉ុន្តែគាត់ទៅរកអែបគេដឹដែរ។ ទៅនៅអែបដើម្បីអ្វី អែបដើម្បីចង់ធំ អែបដើម្បី ព្រោះសម័យនោះដល់អាត្មាពិចារណាមើល ដែលអាត្មាបួសមក សម័យនោះគិតតែមួយរួចខ្លួនទេ។ សម័យនោះនរណាដូចនរណាទេ គិតតែមួយរួចខ្លួនទេ។ គិតតែពីឲ្យធ្វើម៉េចកុំឲ្យគេវាយចោលនេះ១ ឲ្យបានស៊ីឆ្អែតនេះ២ គិតតែជីវិតឯងមួយនេះប៉ុណ្ណឹងឯង។ មិនថានរណាទេ ព្រោះមនុស្សលួងណាស់។

ឡុង ដានីៈ ហើយ តាខូ ហ្នឹង កាលព្រះអង្គឃើញគាត់កាលពីសម័យព្រះអង្គទៅព្រៃមាន់ ទៅភ្នំលាបអីហ្នឹង ឃើញគាត់ធ្វើការអ្វីជាមួយយាយថែម ដែរ?

អឿយ ពឿៈ ជិះតែម៉ូតូឌុប យាយថែម នោះឯង។

ឡុង ដានីៈ ជិះម៉ូតូឌុប យាយថែម?

អឿយ ពឿៈ ជិះតែម៉ូតូឌុប យាយថែម នោះឯង។

ឡុង ដានីៈ ឌុបយាយ ថែម?

អឿយ ពឿៈ ឌុបទៅមកៗ គ្រាន់...

ឡុង ដានីៈ អូ៎! គាត់ធ្លាប់ឌុបយាយថែម ដែរ?

អឿយ ពឿៈ ឌុបតើ។ គេប្រើគាត់ធ្វើអញ្ចេះហើយ គេប្រើឲ្យឌុបអញ្ចេះអញ្ចេះ ទៅលិចទៅនោះគេប្រើណា។

ឡុង ដានីៈ ព្រះអង្គឃើញផ្ទាល់ភ្នែកហ្នឹង ឃើញថា តាខូ គាត់ឌុប?

អឿយ ពឿៈ ឃើញតាមផ្ទាល់។

ឡុង ដានីៈ ឃើញតាមផ្ទាល់ ឃើញ តាខូ ..............

អឿយ ពឿៈ ឃើញតាមផ្ទាល់ គេប្រាប់ថានេះនីរសារយាយថែម។ តាខូ ថាឈ្មោះខូ។ ប៉ុន្តែថារឿងនីរសារមែនមិនមែន អាត្មាក៏មិនដឹង។ អាត្មាក៏មិនបានទៅសួរថា នេះឈ្មោះ ខូពិត ឬមែនពិតមិនមែន .......

ឡុង ដានី: តាខូ យើងនៅត្រពាំងធ្លកនេះហ្នឹង?

អៀយ ពឿ: ហ្នឹងហើយ! អាត្មាក៏មិនដឹង

ឡុង ដានី: ប៉ុន្តែ ដឹងថា គាត់ធ្លាប់ឌុប យាយថែម?

អៀយ ពឿ: ដឹងថា ដឹងថាគាត់ធ្លាប់ ប៉ុន្តែឲ្យថាតាខូ មានភារៈកិច្ចអ្វី អាត្មាថាមិនមានទេ តាខូៗ

ឡុង ដានី: អត់មានទេ ។

អៀយ ពឿ: ព្រោះថា តាខូ ពាយ័ព្យនេះឯង ។ ពួកពាយ័ព្យ សូម្បីតែគណៈតំបន់ ភូមិភាគយក ទៅវាយចោលអស់ គិតមើល?

ឡុង ដានី: ករុណា!

អៀយ ពឿ: មានស្អីនៅបាន ។ ហ្នឹងកាលនិរតីចូលមក ដែលចាប់ ដែលចាប់ណា មិនមែននិរតីចូល មកចាប់ណា ឲ្យពាយ័ព្យនេះឯង ចាប់ពាយ័ព្យ ។

ឡុង ដានី: ឲ្យពាយ័ព្យអ្នកចាប់?

អៀយ ពឿ: ឲ្យពាយ័ព្យអ្នកចាប់ ដល់ចាប់ៗៗទៅអស់ ចាប់អ្នកចាប់នេះហើយ យកទៅក្រោយ គេ ។

ឡុង ដានី: ករុណា! ហើយព្រះអង្គកាលហ្នឹងបាន ដែលធ្លាប់ស្គាល់ថា តាខូ បាននិយាយជាមួយ តាខូ អត់ កាលពេលហ្នឹង?

អៀយ ពឿ: ទេ! អត់បាននិយាយទេ ។

ឡុង ដានី: បានស្គាល់ បាននិយាយគ្នាឆ្នាំណាទៅ?

អៀយ ពឿ: ឆ្នាំនេះឯង មកនៅនេះឯង មកសួរគាត់ ប្រវត្តិគាត់ទៅ ។ គាត់ប្រាប់ សង្ស័យណា ។

ឡុង ដានី: ករុណា!

អៀយ ពឿ: ដែលយើងធ្លាប់ឃើញគ្នាទៅ សង្ស័យ សង្ស័យទៅ សួរប្រវត្តិថា តាខូៗ ឯងធ្លាប់ នៅភ្នំលាបនោះទេ? ធ្លាប់នៅតើ ខ្ញុំនៅជាមួយយាយថែម ។ ថាម៉េចបាននៅ ជាមួយ? ចុះពាយ័ព្យគេដកទៅអស់ទៅ ខ្ញុំសម្រាប់គេប្រើ មិនមានការងារអីធ្វើ ។ គាត់ប្រាប់ត្រង់អញ្ចឹងណា បានអាត្មាដឹងថាមែន ដឹងថាតាខូ មែន ។ គាត់ដឹងថា តាខូ អ្នកពាយ័ព្យ ។

ឡុង ដានី: ដល់ពេលព្រះអង្គសួរគាត់ទៅ គាត់ប្រាប់ថាអញ្ចឹង?

អៀយ ពឿ: គាត់ប្រាប់ ។

ឡុង ដានី: គាត់ថា គាត់នៅជាមួយយាយថែម!

អឿយ ពឿៈ ហ្នឹងហើយ! នៅជាមួយយាយចែម ។ ដល់សួរទៀតទៅគេប្រាប់ថា គាត់នៅជាមួយយាយចែម ម៉ែនហើយ ប៉ុន្តែគាត់គ្មានធ្វើស្អី ដូចថាមនុស្ស មនុស្សយកតែម៉ារស់! ឲ្យតែរស់ ។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ មានអី មនុស្សរកតែម៉ារស់ ។

ឡុង ដានីៈ ព្រះអង្គក៏មានពុធដិកាប្រាប់គាត់ថាធ្លាប់ទៅ...?

អឿយ ពឿៈ ហ្នឹងហើយ! ធ្លាប់ទៅមើល ។ ថាអាត្មាកាលនៅព្រៃមាន់ ទៅមើលគុកភ្នំទ្រយោងតើស ថាព្រះករុណាម៉េចស្គាល់ បើយើងមិនដែលនៅគ្នាផងបានអីស្គាល់ ទាល់តែយើងសាកសួរគ្នាទៅបានយើងស្គាល់ អាត្មាថាអញ្ចេះ ។ អាត្មាថាទៅវាស្ងួតចិត្ត នៅពេលអាត្មាទៅឃើញកន្លែងណាដែលវាសង្វែកចិត្ត សង្វែកណាស់ ព្រោះគិតឃើញឯង ឯងកំពុងអាគេប្រុងតែសម្លាប់ចោលដែរ ព្រោះឪឯង គេថាឪឯងក្បត់ជាតិណា ។

ឡុង ដានីៈ កុរណា! ហើយ តាខូ គាត់ស្គាល់គុកភ្នំទ្រយោង ដែរ?

អឿយ ពឿៈ ដែលមិនស្គាល់ម៉េច បើមនុស្សនៅហ្នឹងឯង ។ ឲ្យតែអ្នកភ្នំលាប ស្គាល់ម៉ត់ហើយ អ្នកភ្នំលាបនោះ ។

ឡុង ដានីៈ កុរណា!

អឿយ ពឿៈ ឲ្យតែអ្នកភ្នំលាប ស្គាល់ម៉ត់ហើយ ។

ឡុង ដានីៈ ប៉ុន្តែ គុកភ្នំទ្រយោងហ្នឹង កើតតាំងពីពាយ័ព្យ ឬក៏កើតជំនាន់និរតីនេះទេ?

អឿយ ពឿៈ និរតីនេះឯង ។ លឺជំនាន់និរតីនេះឯង ។ បើតាមត្រូ ត្រូជំនាន់និរតីនេះឯង ។

ឡុង ដានីៈ និរតី!

អឿយ ពឿៈ ព្រោះពាយ័ព្យអត់ទាន់មានធ្វើសង់អីទេ មានតែសង់ស្ពាន សង់មុខទ្វាត្រពាំងថ្មមួយប៉ុណ្ណេះឯង ។ ដល់និរតីចូលមកបានរើរស្ពាន ។ រើរស្ពានសម័យបារាំងធ្វើ ស្ពានជប៉ុនរើរស្ពានដែកនោះ ។

ឡុង ដានីៈ ស្ពាននៅណា? ស្ពានណា?

អឿយ ពឿៈ ស្ពានដែកយើងសម័យដើម សម័យពីដើម ។ ស្ពានថ្នល់ទៅសៀមរាបណា ។ ស្ពានដែកនោះ ។

ឡុង ដានីៈ អ៊ូ! នៅកន្លែងជាប់ស្រុកក្រឡាញ់ហ្នឹង?

អឿយ ពឿៈ ហ្នឹងហើយ! ឲ្យតែស្ពានដែកចាប់ពីស្វាយទៅ រើរទៅម៉ត់ ។

ឡុង ដានីៈ ម៉េចបានរើរអញ្ចឹង?

អៀយ ពឿៈ   វើរប្រុងធ្វើថ្មីទៀត ៗ

ឡុង ដានីៈ   វើរប្រុងធ្វើថ្មី!

អៀយ ពឿៈ   វើរប្រុងធ្វើថ្មីទៀត ៗ នេះបានថា បានដល់វើរស្ពាន មិនបានដល់ប៉ុន្មានខែផង វាកើត បានថា វាកើតស្រុកយើងឯរាជ្យណា ៗ

ឡុង ដានីៈ   ករុណា!

អៀយ ពឿៈ   ដល់រដ្ឋាភិបាលយើងមានរំដោះបាននេះ អាត្មាថា កន្លែងនីមួយៗ មានអ្នកធ្វើនេះ មានអ្នកក្បត់ទៀត មានអ្នកក្បត់ហ្នឹងនិរតីទៀត មានអ្នកក្បត់ហ្នឹងផែនការនេះទៀត ៗ ហេតុអ្វីបានជាស្រុកកើតសង្គ្រាម ហេតុអ្វីបានជាវើរស្ពាន ៗ អាត្មានឹកឃើញថាវា អាត្មានឹកឃើញថា ស្ពាននោះនៅប្រើកើត ហេតុអ្វីបានវើរធ្វើថ្មី បានអាត្មាថា ៗ ដល់ យូរមិនឆាប់ ពួស្វូរកាំភ្លើងគ្រឹមៗ ៗ ៗ អាត្មារត់ពីព្រៃមាន់មក ថ្ងៃប៉ុណ្ណោះដល់ភូមិ ៗ

ឡុង ដានីៈ   ដល់ភូមិម្កាក់ នៅម្កាក់?

អៀយ ពឿៈ   ហ្នឹងហើយ ដល់ភូមិឈូក

ឡុង ដានីៈ   ករុណា! ភូមិឈូក ៗ

អៀយ ពឿៈ   ថ្ងៃប៉ុណ្ណោះដល់ ៗ រត់ដង្ហែរគ្នាអីចឹង

ឡុង ដានីៈ   ៧៩ ពេលយួនចូលមក?

អៀយ ពឿៈ   ពេលយួនចូលមកហ្នឹង អាត្មារត់ដង្ហែរគ្នាទៅ

ឡុង ដានីៈ   អើម! រត់ហើយ …

អៀយ ពឿៈ   ហើយរថក្រោះដាក់ពីងៗ ៗ ៗ បាញ់ៗ មិនឲ្យចុះ ៗ

ឡុង ដានីៈ   ហើយឆ្នាំណា បានមកជួបតាខូ នេះ?

អៀយ ពឿៈ   អ៊ូ! ឆ្នាំ អាត្មា បួសហើយ ៩៨ ៗ

ឡុង ដានីៈ   ៩៨!

អៀយ ពឿៈ   អាត្មាមកបួសហើយ ៗ

ឡុង ដានីៈ   បួសហើយ ដល់ពេលតាខូមកវត្ត?

អៀយ ពឿៈ   ហ្នឹងហើយ! អាត្មា អ្នកស្រុក គេស្គាល់អាត្មាច្រើន ព្រោះអាត្មាធ្លាប់ទៅនៅនោះ ស្គាល់គាត់ ស្គាល់យូរគ្រាន់ហើយ ប៉ុន្តែថា ស្គាល់ថា ស្គាល់ដូចដីរណា ៗ

ឡុង ដានីៈ   ករុណា!

អៀយ ពឿៈ   ស្គាល់មិនបាននិយាយ មិនបានអីគ្នា ព្រោះថា អាត្មាធ្លាប់នៅ អាត្មាធ្លាប់ធ្វើសង្គ្រាម សម័យយើងថា តស៊ូព្រៃ ៗ អាត្មានៅនោះឯង គេស្គាល់អាត្មាច្រើន ៗ

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ គាត់ក៏ស្គាល់អាត្មា ។

ឡុង ដានីៈ ហើយព្រះអង្គ ពេលដែលបែក៧៩ រត់មកដល់ស្រុកហើយយ៉ាងម៉េចទៀតទៅ?

អឿយ ពឿៈ នៅភូមិនេះឯង ។

ឡុង ដានីៈ នៅភូមិ!

អឿយ ពឿៈ នៅភូមិម្ដាយ មកដល់គោក៏មិនមាន ។ គោក៏មិនមាន គោបាត់អស់ រកឃើញរទេះ ។ ដល់ទៅក៏ចាប់គោមេនៅក្រោលមក ក៏បររទេះ ដឹកអង្កររួច៣បាវ ។ ដឹកទៅនៅខាងកើតស្រុក ។ ថ្ងៃនោះ គេផាប់អស់ទៀត ថ្ងៃនោះ ។ នេះបានអាត្មាជឿទៅលើបុណ្យ ទៅលើបាប ។ ថ្ងៃនោះ ពួកយួនចូលមក កំពុងតែដេកៗ យួនចូលមក ។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ យួនចូលមក ចាប់អាត្មា ។ ចាប់អាត្មា អាត្មារលាស់អញ្ចេ៎ះ ។ អាត្មារលាស់ថា ចាប់អីមានណាបររទេះ ។ អាត្មាថាអញ្ចឹង ។ ហើយវាទៅចាប់អ្នកផ្សេងចាប់ចងៗៗៗបាន ឲ្យជូនផ្លូវគេ ។ ជូនផ្លូវនេះមកផាប់នៅកន្លែងផ្លូវម្នាក់ឡើងរពោក ។ វាមិនរត់ទៅតាមយួននោះ ។ វាមិនរត់ទៅតាមនោះ ។

ឡុង ដានីៈ អត់រត់តាមយួន?

អឿយ ពឿៈ អត់រត់តាម ក្រាបណា ។ ក្រាប យួនវាមិនដឹងភូមិសាស្ត្រអី វាដើរតែតាមដែនទីវា ឆ្លងត្នោតព្រុច ទៅតាមអាងម្នាក់ ឯនេះនៅក្រាប នៅក្រាប ខ្មែរក្រហមពីក្រោយមក ដល់បាញ់ដាក់ក្បាលផុសៗៗៗ ។

ឡុង ដានីៈ បាញ់ប្រជាជន?

អឿយ ពឿៈ បាញ់ប្រជាជន ។

ឡុង ដានីៈ ខ្មែរក្រហមអ្នកបាញ់?

អឿយ ពឿៈ ខ្មែរក្រហមអ្នកបាញ់ ។

ឡុង ដានីៈ អើម!

អឿយ ពឿៈ ថ្ងៃប៉ុណ្ណេះ ដេក អាត្មាថា អ៊ូ! បើកុំតែអាត្មារើរ កុំអីអាត្មាត្រូវផាប់នោះហើយ ។

ឡុង ដានីៈ អើម!

អឿយ ពឿៈ មើលនេះ វាមកចាប់អាត្មា យួនវាមកចាប់អាត្មា ។ អាត្មារលាស់ថា យកទៅធ្វើអី មាននរណាបររទេះ ។ វាទៅចាប់អីនោះទៀត ចាប់ចងៗៗៗ ។

ឡុង ដានីៈ វាចាប់ចងឲ្យនាំផ្លូវ?

អឿយ ពឿៈ ចាប់ចង ៗ ៗ នាំផ្លូវ ។ ចងមិនតឹងទេ ចងកណ្តាចសារ៉ុងនោះ ។ កណ្តាចសារ៉ុងមនុស្សប្រុសយើងណា ។

ឡុង ដានីៈ អាអីគេ កណ្តាច?

អឿយ ពឿៈ កណ្តាច ។

ឡុង ដានីៈ កណ្តាច!

អឿយ ពឿៈ ហ្នឹងហើយ! កណ្តាច វាហែកខ្វែកៗ ៗ យកសារ៉ុងដែលស្លៀកណា ។ ឃើញទាំងហែកទៀត

ឡុង ដានីៈ សារ៉ុង?

អឿយ ពឿៈ ហ្នឹងហើយ! សារ៉ុងណា

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ សារុងមនុស្សប្រុស ។ អាត្មាឃើញទាំងហែកទៀតនោះ ។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ ព្រោះគេចាប់ចងៗ ៗ អាត្មាដឹកគោទាញអ៊ញ៉ុះ ។ ចុះវាបាញ់ទីងៗ ៗ ៗ ៗ ។ អាត្មាចាប់គោបានទាញ អាត្មាបរចេញទៅអីចេះ ទៅដល់គេហៅគោកទ្រលបានអាត្មាឈប់ ។ អាត្មាឈប់ ថ្ងៃប៉ុណ្ណេះ បានមានអ្នករស់រត់ទៅ ថាងាប់អស់ហើយ ។

ឡុង ដានីៈ ចុះ ព្រះអង្គឆ្នាំណាបានព្រះអង្គចូលធ្វើទាហានអីទៀត?

អឿយ ពឿៈ ប្រហែលជា ៨៨-៨៩ ព្រោះកាលហ្នឹងនោះ នៅកាលដែលយួនទើបចូលមក អត់ទាន់បានធ្វើទេ ។ គ្រាន់តែអ៊ញ៉ុះ គ្រាន់តែមានចលនា គ្រាន់តែមានចលនាថា តស៊ូថាពុ្ទ នេះពុ្ទគេណា នេះហើយគេថាអ្នកល្ងង់ ។ អ្នកល្ងង់គេនាំឲ្យងាប់ ងាប់ហើយ ។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ អ្នកល្ងង់នាំឲ្យងាប់ ងាប់ហើយ ។ មិនបានផលអ្វីទេ ។ គេបើកណាស់ គេបើក គេបង្កើតជំរុំ បង្កើតជុំរំនៅតាមទល់ដែនណា ។ ជំរុំនងច័ន្ទ គោកញ្ញ៉ ជំរុំអាសាលាណៃ ជំរុំចាស់ ជំរុំគោកស៊ូជំរុំថ្មី បឹងអំពិល ។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ គេឲ្យអាត្មានេះ សុទ្ធតែបងប្អូនហ្នឹង វារត់មកពីថៃ នឹកឃើញ នឹកឃើញ បានជួបពុកឯងវិញ ។ ដឹងថាពុកឯងមិនងាប់ទេ ដឹងថាពុកមិនងាប់ហើយ ។ ដឹងថាមិនងាប់ទេ ។ ប៉ុន្តែគេមិនប្រាប់ទេ អ្នកមកមុនគេមិនប្រាប់ទេ តែបងប្អូនឯងគេ មិនប្រាប់ថាលោកពុកនៅរស់ ហើយទៅធ្វើហ្នឹងគេ ។ ទៅធ្វើហ្នឹងគេ អាត្មាដូចជា ដូចអាត្មាតែងនិយាយ

ថាអាត្មាជឿណាស់បុណ្យ ។ ដល់ធ្វើទៅឃើញទិដ្ឋភាពគេមានតែប្លន់មានតែបាញ់គ្នាឯង ដណ្ដើមបុណ្យសក្ដិ ។ អាត្មាក៏គេចចេញ គេចចេញពីកន្លែងដុំរំចាស់នោះ ទៅនៅភូមិវិញ អាត្មាថាមិនកើតទេពួកនេះដណ្ដើមតែបុណ្យសក្ដិគ្នា អ្នកមិនដែលធ្វើធំផង ចង់ធ្វើតែធំ បាញ់គ្នាឯង សម្លាប់គ្នាឯងផាប់ ។ ដល់ពេលសម័យក៥ សម័យក៥ បានបង សម្បត្តិគាត់យកទៅទុកហ្នឹង ។

ឡុង ដានី: សម្បត្តិណា?

អឿយ ពឿ: សម្បត្តិយើងប្រធានយោធាស្រុកណា?

ឡុង ដានី: ឈ្មោះអីសម្បត្តិ?

អឿយ ពឿ: ប៉ូ សម្បត្តិ ។

ឡុង ដានី: ប្រធានយោធាស្រុក?

អឿយ ពឿ: ប្រធានយោធាស្រុកស៊ីសូផុនណា ។

ឡុង ដានី: ករុណា!

អឿយ ពឿ: គាត់យកទៅទុក គាត់ឲ្យសិក្ខាម៩០នាក់ ។ ពួកអាត្មានៅភូមិ ស្រុកស៊ីសុផុន ចាប់ពីឆ្នូលរពាក់ គោគស្វាយ ខ្មែរ ខ្ពស់ ដើរវ៉ៃជាមួយទាហាន ប៉ុន្តែអាត្មាទៅមិនដែលវ៉ៃទេ តាំងពីប្រសាទតាំងពីអី វ៉ៃគ្នាមិនដែលបានវ៉ៃយូរទេ មួយព្រាវៗៗ ពួកខ្មែរក្រហមពួកប៉ាវ៉ាវ៉ាដេញ ។ វ៉ាដេញថាខ្មែរ ស្គាល់ភូមិសាស្ត្រច្រើន ។ ហើយអាត្មាដឹងតាកតិចពួកនោះទៀត អាត្មាដឹងតាកតិចពួកទ័ពព្រៃទៀត ។ អាត្មាដឹងថាពួកនេះដែលមានក្រឡាបើយ៉ាងណា៣០០គ្រាប់ហ្នឹងមកម៉ាដើមទ្រូង អាត្មាដឹង ។ ដល់នេះទៅវ៉ាខ្លាចនេះឯង គ្មានសូវហ៊ានពួកអាត្មាទេ ។ ពួកអាត្មាសុទ្ធតែអាសេកាសេ បេលាយអាសេកាសេ ។ បានគាត់ហៅឡើងទៅវិញ ចុះប្រតិបត្តិការ១ខែកន្លះ បានគាត់ហៅឡើងទៅវិញ អាត្មានឹកឃើញសព្វៗថា អាត្មានឹកថាមិនឲ្យនរណាកើយបានទេ ប៉ុន្តែអាត្មាមិនលោភមិនលន់អីទេ ប៉ុន្តែរឿងគេកើយលើមិនបានហ្នឹង ។ គិតទៅនៅនេះមិនបានប្រយោជន៍អ៊ីទេ ។ បានប្រយោជន៍តែគេអ្នកធំនេះឯង ។ បងខ្ញុំសុំទៅផ្ទះវិញហើយ ។ អញមិនឲ្យឯងទៅទេ ។ អាត្មាធ្វើជាឈឺពោះ ។ គាត់សួរថា កើតអីឯងឈឺពោះ ។ ខ្ញុំគេថាខ្លួនណាបង សុំបងឯងទៅផឹកថ្នាំ នេះគាត់ក៏ធ្វើសំបុត្រឲ្យទៅ ។ មេឃុំក៏គេមិនហ៊ានប្រើមេភូមិក៏មិនហ៊ានប្រើឡើង៣ឆ្នាំណា ។ បានអាត្មាឲ្យសំបុត្រទៅមេឃុំ ។ យកសំបុត្របំពេញសកកម្មទៅឲ្យមេឃុំ ។ មេឃុំថាម៉េចក៏ឯងទៅកន្លែងវិញទៅ? ខ្ញុំថាមិនទៅទេ ។ បានក្រោយមកទៀត បានគេដកគាត់ជាមួយសម័យស៊ីនតុ ទៅបាត់ដំបង ។ គាត់ឈប់

នៅខេត្តបន្ទាយមានជ័យគាត់ទៅនៅណុះទៀត ។ គេបង្កើតបន្ទាយមានជ័យនេះ គេដកគាត់ទៅបាត់ដំបង ។ សព្វថ្ងៃនេះបែកគ្នាមិនបានឃើញគាត់ ចាស់ប៉ុណ្ណឹងប៉ុណ្ណោះទេ ។ ហើយអាត្មាមិនដែលសួរត្រូវហ្នឹងអ្នក មិនដែលសួរហ៊ានទៅបៀតបតគេផង អ្នកមាននេះ១ អ្នកធំនេះ២ ។ អាត្មាមិនដែលហ៊ានទៅបៀតបតគេទេ ។

ឡុង ដានីៈ ចុះព្រះអត់ដែលធ្លាប់ធ្វើចូលខាងទាហានប៉ារ៉ាទេ?

អឿយ ពឿៈ ធ្វើតើ! ដូចអាត្មានិយាយថាមុននោះ ។

ឡុង ដានីៈ និយាយមិញក្រែងទាហានខាង?

អឿយ ពឿៈ អាណោះក្រោយ! និយាយថាមុន និយាយពីគោខ្យង និយាយពីភ្នំចាស់ ភ្នំថ្មីណា ។ អាត្មាមើលទៅវាអត់ស្អាត វាមានតែបាញ់គ្នា វាមានតែស្រី វាមានតែ...

ឡុង ដានីៈ អ៊ូ! បានន័យថា ធ្វើទាហានប៉ារ៉ាមុនហើយ បានចូលក្នុងវិញ ។

អឿយ ពឿៈ ធ្វើមុន ។ មើលទៅមិនស្អាត ។

ឡុង ដានីៈ កាលហ្នឹង ទាហានប៉ារ៉ានៅខាងណា?

អឿយ ពឿៈ ជំរុំចាស់ ។

ឡុង ដានីៈ ជំរុំចាស់! ខាង សឺន សាន?

អឿយ ពឿៈ វ៉ែន សារ៉ែន ។

ឡុង ដានីៈ ប៉ុន្តែអត់ដែលមកឈរជើងនៅខាងបន្ទាយឆ្មារនេះទេ?

អឿយ ពឿៈ អត់ទេ ។

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ កាលហ្នឹងអត់ទាន់បានមកទេ ។ គ្រាន់តែបើកជំរុំបាន បានមនុស្សទៅពេញណាពេញណី កើតបាញ់គ្នាឯងនេះ ។ កើតបាញ់គ្នាឯងហើយ បានអាត្មានឹកឃើញថា មិនកើតទេ ពួកយើងតែនៅដឹងតែស្លាប់ហើយ ព្រោះថាគេ ពួកមនុស្សគេគោរពអ្នកធំណាស្រួលមិនស្រួលគេឲ្យបាញ់ឯងសម្រេះមួយថ្ងៃមួយៗ ។ បងប្អូនអាត្មាក៏នាំគ្នាទៅវិញបាន ៤-៥ នាក់ ។ នៅមួយដែរ នៅអាឃួង ស្លាប់ម៉ែន ។ អានោះ អនុ តាសារ៉ែន ។ តាសារ៉ែន ខ្លាចអានោះឯងធំជាង បានបាញ់អានោះចោល ។ បានអាត្មានាំវាទៅខ្លាចវាមិនទៅ ។ អានោះវាមិនដែលធ្វើ វាតាំងពីតូច វាកូនកំព្រានោះ ឪវាស្លាប់ម៉ែវាបានប្ដីទៀត ។ វានៅតែជាមួយទាហាន ។ អញទៅមិនកើតទេ នាំវាទៅក៏ទៅៗ ។

ឡុង ដានីៈ ហើយព្រះអង្គ ដល់ពេលអញ្ចឹង ចេញពីខាងប៉ារ៉ាទៅ ដល់ឆ្នាំ៨៨ បានទៅធ្វើទាហាននៅខាងក្នុងវិញ?

អឿយ ពឿៈ ពរ! អាដែងគេចល័តក៥ណា ។ ក៥បានគេហៅអាត្មាទៅ ។ គេហៅអាត្មាទៅនោះ គេមិនដឹងជាគេទៅបញ្ជូនអាត្មាទៅក៥ មិនដឹងជាស្អីទេ ។ ប៉ុន្តែបែបគេខ្វះកម្លាំងបាន គេឲ្យកម្លាំង៩០នាក់ ។

ឡុង ដានីៈ កាលហ្នឹង ព្រះអង្គអត់ទាន់បួស ព្រះអង្គមានគ្រួសារដែរអត់ទេ?

អឿយ ពឿៈ មានតើ ។

ឡុង ដានីៈ ព្រះអង្គមានគ្រួសារដែរ ។

អឿយ ពឿៈ មាន ។

ឡុង ដានីៈ គ្រួសារ មានកូនចៅទេ?

អឿយ ពឿៈ មានតើ ។

ឡុង ដានីៈ មានប៉ុន្មានអ្នកដែរទៅ?

អឿយ ពឿៈ ៥នាក់ដែរ ។

ឡុង ដានីៈ ៥នាក់ ។ គ្រួសារព្រះអង្គ ឈ្មោះអ៊ីទៅ?

អឿយ ពឿៈ ឈ្មោះ ចាប ។

ឡុង ដានីៈ ឈ្មោះ ចាប ។ គាត់នៅណាសព្វថ្ងៃ?

អឿយ ពឿៈ នៅត្របែក ។

ឡុង ដានីៈ នៅត្របែក! ត្របែកក្នុងស្រុកអីគេហ្នឹង?

អឿយ ពឿៈ ស្រុកព្រះនេតព្រះសព្វថ្ងៃ

ឡុង ដានីៈ សព្វថ្ងៃនៅព្រះនេតព្រះ ។ ឃុំអីគេនៅហ្នឹង?

អឿយ ពឿៈ ឃុំបុសស្បៅ ។

ឡុង ដានីៈ ឃុំបុសស្បៅ ។ ហើយព្រះអង្គបោលសាងភ្នួសបួសនេះពីឆ្នាំណាមក?

អឿយ ពឿៈ ពី ៩៨

ឡុង ដានីៈ ៩៨! បួសនៅវត្តហ្នឹង តែម្តង ឬក៏មកពីខាងព្រះនេតព្រះ?

អឿយ ពឿៈ បួសនៅវត្តនេះឯង ។

ឡុង ដានីៈ បួសនៅវត្តនេះ ។

អឿយ ពឿៈ បួសនៅវត្តនេះឯង ។

ឡុង ដានីៈ មកពីបុសស្បៅមកនេះបណ្តោយ?

អឿយ ពឿៈ ពរ! អាត្មានិយាយមុនអាត្មាបួសទៅចុះ ។ មុនអាត្មាបួសនេះ ជ្រុលនិយមណាស់ ដែលគេថាជ្រុលនិយមណាស់ ។ គេក៏មកអង្វរអាត្មា គេមកអង្វរអាត្មាថាឲ្យអាត្មាធ្វើ

ជាមួយគេពួកទាហានដែលគេទៅនៅព្រៃណា។ អាត្មាថា អាត្មាមិនធ្វើទេ អញមិនធ្វើទេ ខ្ញុំមិនធ្វើទេ ប្រាប់គេ។ ប្រាប់ទៅគេក៏ចេះតែអង្គរឲ្យធ្វើ។ ដល់ធ្វើ អាត្មាដឹងថាធ្វើម៉េចឈ្មោះ វាមានស្អីៗហ្នឹងឈ្មោះ អាត្មាដឹងថា ពេលស្រុកដែលមានសង្គ្រាម គេរត់រកមនុស្ស។ ពេលដែលគេបានសប្បាយ គេសប្បាយតែគ្នាគេ។ អាត្មាថាអញ្ចឹងពួកនោះគេមិនស្តាប់ ថាអើធ្វើក៏ធ្វើ ធ្វើបានអាត្មាធ្វើ បានវៃចាញ់គេឡើងទៅនៅគេហៅឡាក់ ២៧។

ឡុង ដានី៖ ឡាក់ ២៧?

អឿយ ពឿ៖ ឡាក់ ២៧។ ដល់ទៅនៅឡាក់ ២៧ អាត្មាងាប់។ អាត្មាងាប់៣យប់៣ថ្ងៃ។ រុំយពងដាក់មាត់អស់។

ឡុង ដានី៖ ភ្លឹកទៅ?

អឿយ ពឿ៖ ហ្នឹងហើយ! រុំយពងដាក់មាត់អស់។

ឡុង ដានី៖ ម៉េចបានអាហ្នឹងម៉េច?

អឿយ ពឿ៖ វាមិនកើតអីទេ អគ្គុយៗៗ គ្នាអញ្ចេះឯងដូចជា ហៅថា បើយើងធម្មតាថា ប្រសៃរប្រសាទណា ប៉ុន្តែមិនមែនប្រសៃរប្រសាទទេ។

ឡុង ដានី៖ ភ្លឹកទៅហ្នុង?

អឿយ ពឿ៖ អគ្គុយៗៗៗ ឃើញដែនដីផ្លាស់ ដែនដីផ្លាស់ មេឃអីក៏ផ្លាស់ទៅជាខៀវអស់។ មានមនុស្សអ៊ូរអរភ្លាម។ ប្រាប់គេថា អញគេមកយកហើយ។ អ៊ូ! ម៉េចនិយាយអញ្ចឹងប្រាប់កូនចៅថាអឹម៉េចបាននិយាយអញ្ចឹង។ និយាយអញ្ចឹងអីមែនអញងាប់ថ្ងៃហ្នឹងហើយ។ អញងាប់ថ្ងៃនេះហើយ ចាំមើលទៅ។ ប្រាប់គេថា បើមិនជឿអញចាំមើលអញស្រែក។ បើមិនជឿថាអញងាប់ទេ ចាំមើលអញស្រែក។ មុនហ្នឹងអញងាប់នេះអញពូកែណាស់ ចាំមើលអញស្រែកឲ្យខ្យល់បាក់មេឃ ស្រែកវ៉ូវៗ ចាំបានអាកន្លែងស្រែក។ ស្រែកវ៉ូវ មាន់នៅក្នុងនៅក្នុងដុបអីបោលព្រូចោលទៅក្រោមផ្ទះអស់។ ខ្យល់បាក់មែកឈើប្រាវៗ។ បានស្រើៗស្រែកថា ឈប់ទៅអ៊ុំអើយប៉ុណ្ណឹងបានហើយ ចុះអញងាប់នៅ អញ្ចេះអញផ្តាំ បើមិនទាន់គ្រប់៧ថ្ងៃកុំទាន់ដុតអញណា។ ក្មេងៗវាថាបាទអ៊ឹ។ បានឡើងលើគ្រែទៅ។

ឡុង ដានី៖ ករុណា!

អឿយ ពឿ៖ អាត្មាដឹងហើយផ្លូវងាប់នោះ។ បានអាត្មាជឿបាប ជឿបុណ្យ អាត្មាមកបួសនេះណា

ឡុង ដានី៖ ករុណា!

អឿយ ពឿៈ ផាប់កើត ប៉ុន្តែមិនដឹងថាកើតជាអ៊ី?

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ ផាប់កើត ៗ ផាប់មានគ្រឿងដឹង គ្រឿងដឹងថាឯងផាប់ ប៉ុន្តែរូបនេះអត់ដឹងទេ ប៉ុន្តែមានគ្រឿងដឹង ៗ

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ ភ្លឹបទៅមានរូបមួយ ៗ

ឡុង ដានីៈ ញាណយើង?

អឿយ ពឿៈ ហ្នឹងហើយ! ញាណឯងនោះដូចរូប ដឹងថា អ៊ូ! អញផាប់បាត់ អញកើតខ្មោចបាត់ ៗ អញមុខតែនរកទូងហើយ ៗ នឹកឃើញធម៌២ម៉ាត់ ដែលតាអាចារ្យគាត់តែងប្រាប់យាយ ៗ ឲ្យទន្ទេញ ៗ ធម៌នេះ ធម៌ជួយបានមែន ៗ ដែលមកបួសនេះ បួសជឿធម៌ ៗ ពុទ្ធោ ៗ ៗ ៗ ៗ រហូតដល់បានមកវិញ ៗ កុំថាមិនជឿ មនុស្សផាប់កើត ៗ

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ អាត្មាជឿហើយ ៗ

ឡុង ដានីៈ ករុណា!

អឿយ ពឿៈ កុំអីអាត្មាមិនបួសទេ ៗ

ឡុង ដានីៈ ដល់ពេលព្រះអង្គចេញពីហ្នឹងមក មកហ្នឹង មកបួសនៅហ្នឹង ៗ

អឿយ ពឿៈ មកបួសបណ្ដោយ

ឡុង ដានីៈ បួសកសាងវត្តនេះបណ្ដោយ ៗ

អឿយ ពឿៈ ហ្នឹងហើយ ទេមានគេបួសមុន ៗ គេកសាងមុនហើយ ប៉ុន្តែកាលហ្នឹងមិនទាន់បានអីទេ ៗ ទាល់តែអាត្មាបួសបាន៣ឆ្នាំនោះ បានអាត្មាធ្វើបានខ្លះមានកុដិ មានអី ៗ កាលមុនមិនមានអ៊ីទេ ៗ អាត្មាក៏មិនដែលបានទៅបិណ្ឌបាតទៅអី ទៅរកអីណាទេ ទៅអង្គាសយោសនាឯណាទេ កាលអាត្មាបួសណា ព្រោះអាត្មាមិនប្រឹងទេ បើមាន មានតាមកម្លាំងសទ្ធាចុះ ព្រោះគិតឃើញថា អាត្មាឃើញដែរ ឃើញពួកវត្តខ្លះដែលធ្វើវិហារធ្វើអី អាត្មាក៏ឃើញ ៗ ឃើញថាគ្នាខំណាស់ ៗ ហើយសុំអត់មានគេរមានខ្មាស់ ៗ ហើយ សួរថាត្រូវតាមច្បាប់របស់ព្រះទេ មិនត្រូវទេ ៗ

ឡុង ដានីៈ អត់ត្រូវទេ?

អឿយ ពឿៈ អត់ត្រូវទេ ៗ ព្រះអត់មានឲ្យភិក្ខុសង្ឃអីកសាងកុដិ កសាងវិហារអីទេ គឺថាធ្វើម៉េចប្រតិបត្តិឲ្យតែបានល្អដែលពុទ្ធបរិស័ទគេយកបុណ្យមកផ្ញើរហ្នឹងឯង ៗ ឯងធ្វើម៉េចឲ្យបាន

ល្អ ៗ ធ្វើបានល្អ ធ្វើយ៉ាងណា ធ្វើម៉េចឲ្យបានល្អ ធ្វើកុំឲ្យមានអំពើអាក្រក់ប៉ុណ្ណោះបានហើយ កុំចង់បានណាស់ពេក ៗ យើងចង់បានខ្លាំងណាស់ពេក ទោះបីយើងមិនយកក៏គេថាយើងយកដែរ ៗ

ឡុង ដានី៖ ករុណា!

អៀយ ពឿ៖ គេថាយើងយកដែរ ៗ យើងចង់បានណាស់ពេក ៗ ហើយភិក្ខុដែលចូលមកបួសនេះ..... គេថាអ៊ីខ្លះ សុទ្ធតែលះបង់ទាំងអស់ អ៊ី ៗ ៗ ក៏ត្រូវតែលះបង់ ៗ ដើម្បីអ៊ីដែលចូលមកបួសនេះ? ដើម្បីព្រះនិពាន បានន័យថាដើម្បីព្រះនិពានដែលមកបួសនេះ ៗ អ្នកដែលបួសនេះ ដើម្បីព្រះនិពាន ធ្វើយ៉ាងម៉េចដើម្បីបានព្រះនិពាន គឺលះ ៗ ចុះបើយើងបួសហើយយើងមិនលះ ៗ បើសិនបើយើងលះ ទោះបីបានដល់មិនបានដល់ ក៏ធ្វើតាមពុទ្ធដីការបស់ព្រះដែរ ៗ អាត្មាមិនដែលសុំឯកឧត្តមណាទេ អ្នកមានណាអាត្មាមិនដែលសុំទេ ៗ បើគេចង់ធ្វើធ្វើទៅ បើថាគេសួរថាតេជគុណម៉េចក៏មិនធ្វើវិហារធ្វើអី ៗ វាមិនមានប្រាក់ញោម ៗ ញោមឯងធ្វើធ្វើទៅ បើញោមឯងមានប្រាក់ ៗ បើអាត្មា អាត្មាមិនមានប្រាក់ធ្វើទេ ៗ

ឡុង ដានី៖ កុណា! អរគុណ ព្រះអង្គ ច្រើនដែលរំខានពេលវេលាព្រះអង្គយូរ

អៀយ ពឿ៖ មិនអីទេ ៗ អាត្មាដូចថាអញ្ជើញឯង អាត្មាដូចជម្រាបអញ្ចេះឯង កន្លែងអាត្មាដឹងអាត្មានិយាយបាន ៗ កន្លែងណាអាត្មាមិនដឹង អាត្មាមិនដឹងទេ ៗ

ឡុង ដានី៖ ករុណាអរគុណច្រើនព្រះអង្គ ៗ